ពូច_អ៊ុម

# វេយ្យាករណ៍ខ្មែរ



វ៊ិ.62

សំរាប់

ថ្នាក់បឋមសិក្សា

415

ពូច - អ៊ឹម

សាស្ត្រាចារ្យ

# វេយ្យាករណ៍ខ្មែរ

សំរាប់ថ្នាក់

## មជ្ឈិមដ្ឋាន នឹង ឧត្ដមដ្ឋាន

បណ្ណាគារ គីម សេង ភ្នំពេញ

លេខ ២២៣ វិថីប្រជាធិបតេយ្យ

បោះពុម្ពលើក ទី ៥ ចំនួន ២·០០០ ច្បាប់

ព.ស. ២៥១៥ គ.ស. ១៩៧២

រក្សាសិទ្ធិ

## សារបាន

មាតិកា ... ទំព័រ


វេយ្យាករណ៍ (អក្សរ - ស្រៈ) ... ១
ព្យញ្ជនៈ ... ២
អក្សរអឃោសៈ-ឃោសៈ-សិថិល ... ៣
គូអក្សរ ... ៤
ព្យញ្ជនៈបន្ថែម - វណ្ណយុត្តិ ... ៥
វិធីប្រើវណ្ណយុត្តិ ... ៦
អក្សរព្យញ្ជនៈផ្លាស់ប្ដូររូប ... ១២
វិធីសាធ្យាយចាំមាត់ ... ១៣
វណ្ណយុត្តិ - មេសូត្រ (ព្រហ្មគិត) .. ១៤
ឧច្ចារនៃអក្សរ ... ១៨
ព្យាង្គរបស់ពាក្យ ... ១៩
ព្យាង្គតម្រួត ... ២០
សំឡេងអក្សរអឃោសៈ - ឃោសៈ .. ២១
នាមក្រិត - កិរិយាក្រិត ... ២២
នាម ... ២៥
លិង្គរបស់នាម ... ២៧
វចនៈ ... ២៨
គុណនាម ... ២៩
កិរិយាសព្ទ ឬ កិរិយា ...... ៣១
វិធីកាត់ពាក្យមានបន្តក់នឹងឥតបន្តក់ ៣៣
សព្វនាម ... ៣៤
កិរិយាវិសេសន៍ ... ៣៨
វិធីប្រើអាយតនិបាត ... ៣៩


## សារបាន

មាតិកា ... ទំព័រ


និបាតសព្ទ ... ៤៦
សំខ្យា ឬ សំខ្យសព្ទ ... ៥២
បុព្វបទ ... ៥៤
អាគម - ឧបសគ្គៈ ... ៥៥
សម្ពន្ធ ... ៥៨
សមាសនាម ... ៧៥
ពាក្យកើតពីអក្សរ ឋ ឆ្ន ថ ស្ន ស្ត ស្ថ ៧៨
ព្យញ្ជនៈផ្លាស់រូបតែសព្ទគង់នៅដដែល ៨០
អាខ្វាក់អាខ្វិននាំគ្នារត់ ... ៨២
សុភាទន្សាយ បានសង្គ្រោះត្រី ... ៨៤
វិជ្ជាសម្បត្តិ ... ៨៦
នាងកង្រី ... រិទ្ធិសែន ... ៨៧
សត្វមុងនឹងត្រី ... ៨៩
ស្ត្រីពីរនាក់ដណ្ដើមកូនគ្នា ... ៩០
រឿងខ្លាឃ្មុំនឹងដើមពង្រ ... ៩២
ឆ្មាស្រុកនឹងចាបពួក ... ៩៤
ញៀននឹងថ្នក់រំពាក់នៅដៃ ... ៩៥
រឿងសត្វបង្គួយ ... ៩៧
អមិន្ទបុត្តកៈ ... ៩៨
ស្ទូចត្រី ... ១០០
ផ្ទួមង ត ... ១០១
ដេញហាប់ចោរ ។ ចាប់វិញ ... ១០២

# សេចក្ដីផ្ដើម និង ការយល់ព្រម

ការកើតឡើងជាវិធីអក្សរនេះ ដោយសារខ្ញុំយកចិត្តទុកដាក់ ជាតិកំណើតរបស់ខ្ញុំជាទីស្រឡាញ់ ព្រោះការធ្វើនេះ គឺធ្វើដោយចិត្តឯង ពុំបានគិតកម្លាំងនឿយលំបាកឡើយ ។

វិធីអក្សរនេះ រៀបតែនឹងបោះបង់ចោលអស់សារតែការទៅ ហើយ ស្រាប់តែលោក អ៊ុម-ឈាងស៊ុន ទីប្រឹក្សាព្រះរាជ-អាណាចក្រ កាលលោកនៅជាចាងហ្វាងក្រសួងសិក្សាធិការ ក្រុងភ្នំពេញ លោកមានចិន្តារៀបចំវិជ្ជាខេមរភាសាឲ្យបានរៀបរយ ទើបលោកឲ្យខ្ញុំយកការដ៏តិចតួចនេះជូនទៅលោក ។

ក្បួននេះមានកំណើតជាដំបូងបំផុត របៀបវេយ្យាករណ៍ ពុំបានជាប្រសើរណាស់ណាឡើយ តែខ្ញុំសូមដឹងគុណលោក អ៊ុម-ឈាងស៊ុន ជាទីបំផុតដោយសេចក្ដីដែលលោករាប់អាន ការតិចតួចរបស់ខ្ញុំមិនឲ្យសោះសូន្យ ។ លោកក៏បានចាត់ចែងឲ្យ ក្រុមវិទ្យាសាស្ត្រ ក្រសួងសិក្សាធិការ ពិនិត្យបោះពុម្ពផ្សាយតាម ឃោសនាការ ពីឆ្នាំរកាស័ក ព.ស. ២៤៨៨ មុនរួចហើយ ។

ដល់មកថ្ងៃទី១ ខែសីហា គ.ស. ១៩៥០ នេះ រោងពុម្ពខេមររដ្ឋ ក្រុងភ្នំពេញ បានទៅសុំសៀវភៅនេះអំពីខ្ញុំជាអ្នករៀបរៀង ដើម្បីនឹងយកទៅចាត់ចែងបោះពុម្ពទុកបម្រើដល់សិក្ខាកាម-កុលបុត្រ ដែលស្រេកឃ្លានការសិក្សាអក្សរសាស្ត្រខ្មែរ ជាវយកទៅសិក្សារៀនសូត្រឲ្យបានសម្រេចតាមបំណង ។

ខ្ញុំក៏បានយល់ព្រម អនុញ្ញាតឲ្យរោងពុម្ពខេមររដ្ឋបោះពុម្ពសៀវភៅនេះ តាមសេចក្ដីត្រូវការ ដោយសេចក្ដីសង្ឃឹមថា អក្សរសាស្ត្រខ្មែរ នឹងបានឡើងកាន់វឌ្ឍនធម៌ល្អគួរណាស់ដុះដាលបេស្មើមុខនឹងគេទៅអនាគត ។

ព. ស. ២៤៩៣ គ. ស. ១៩៥០

ញូវ អ៊ុម

---

# វេយ្យាករណ៍ខ្មែរ

១ – វេយ្យាករណ៍ខ្មែរជាក្បួនបង្រៀនវិធីអក្ខរៈ ដើម្បីនិយាយត្រឹមត្រូវ សរសេរត្រឹមត្រូវក្នុងភាសាខ្មែរ ។ ក្បួនវេយ្យាករណ៍ច្រាវក្ដារៀបរៀងតាំងពីព្យញ្ជនៈ ។

អក្ខរៈ ឬអក្សរ ឬវណ្ណៈ មានពីរយ៉ាងគឺៈ ស្រៈ ឬសរៈ និងព្យញ្ជនៈ ។ ស្រៈមានពីរពួក ស្រៈពេញតួ និងស្រៈនិស្ស័យ ។

ស្រៈពេញតួមាន ១៥ គឺៈ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ។

ស្រៈនិស្ស័យមាន ២០ តួគឺ ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។

ព្យញ្ជនៈមាន ៣៣ តួគឺៈ ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ ° ។

ដែលហៅថាស្រៈពេញតួនោះ គឺស្រៈប្រើជាតួអក្ខរៈដូចតួព្យញ្ជនៈដែរ ដូចពាក្យថា: អរគុណ អាប ឥឡូវ កៅអី ឧត្តម ឱស្រាហ៍ ឪឡឹក ឧឡោក ឫក្ស ឫស្ស ឫទ្ធិ ឮឬទេ? ឯក ឯនោះ ឭជំ ឭក ឲ្យ ឧដ្ឋ ឧស្ឋ អក អក់ អាចម៍ ក្រុម អាវ ឥត ។

ដែលហៅថាស្រៈនិស្ស័យនោះ ព្រោះអាស្រ័យនឹងតួព្យញ្ជនៈ



ទើបប្រើបាន ដូចពាក្យថា: កាម ជឹង ចុង កុដិ សូម លេង កាំបិត ប្រែង កន្ទើយ ព្រងើយ សម្បើម ចង់ចាញ់ ។

---

## ២ — ព្យញ្ជនៈ

ព្យញ្ជនៈទាំង ៣៣ ចែកជា ៥ វគ្គឬពួក និងសេសវគ្គ ១ ។ វគ្គនិមួយៗ មានអក្សរ ៥ តួ, ឯសេសវគ្គមានអក្សរ ៨ តួ ។ វគ្គទី ១ គឺ: ក ខ គ ឃ ង ។ វគ្គទី ២ គឺ: ច ឆ ជ ឈ ញ ។ វគ្គទី ៣ គឺ: ដ ឋ ឌ ឍ ណ ។ វគ្គទី ៤ គឺ: ត ថ ទ ធ ន ។ វគ្គទី ៥ គឺ: ប ផ ព ភ ម ។

សេសវគ្គគឺៈ យ រ ល វ ស ហ ឡ អំ ។

ព្យញ្ជនៈទាំងឡាយមានស័ព្ទសំឡេងជាពីរពួក ពួកសំឡេងតូចហៅថាអឃោសៈ ពួកសំឡេងធំហៅថាឃោសៈ ។

## អក្សរអឃោសៈ

ក ខ - ច ឆ - ដ ឋ - ត ថ - ប ផ - ស ហ - ឡ អ ។

## អក្សរឃោសៈ

គ ឃ ង - ជ ឈ ញ - ឌ ឍ ណ - ទ ធ ន - ព ភ ម - យ រ ល វ ។

អក្សរនៅចុងវគ្គទាំង៥ និងនៅចុងសេសវគ្គ ឈ្មោះនិគ្គហិតគឺ ង ញ ណ ន ម អំ ។ តួព្យញ្ជនៈទាំងឡាយមានសំឡេងប្លែកពីគ្នាៈ ខ្លះមានសំឡេងតែមួយ ខ្លះមានសំឡេងធ្ងន់ ។ តួដែលមានសំឡេងតែមួយហៅថាសិថិល, តួដែលមានសំឡេងធ្ងន់ហៅថាធនិត ។

## អក្សរសិថិល

ក គ - ច ជ - ដ ឌ - ត ទ - ប ព - យ រ ល វ ស ហ

និងនិគ្គហិតង ញ ណ ន ម អំ ។

## អក្សរធនិត

**១ឃ - ឆឈ - ឋឍ - ថធ - ផភ ។**

---

## ៣ — គូអក្សរ

ក្នុងវគ្គនិមួយ ៗ មានអក្សរជាគូគ្នាពីរគូ នោះគឺៈ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វគ្គទី | ១ | អក្សរ | ក | ជាគូនឹងអក្សរ | ខ | ។ | គ | ជាគូនឹង | ឃ |
| „ | ២ | „ | ច | „ | ឆ | ។ | ជ | „ | ឈ |
| „ | ៣ | „ | ដ | „ | ឋ | ។ | ឌ | „ | ឍ |
| „ | ៤ | „ | ត | „ | ថ | ។ | ទ | „ | ធ |
| „ | ៥ | „ | ប | „ | ផ | ។ | ព | „ | ភ |

ឯអក្សរនៅសេសវគ្គជាតួសិថិលទាំងអស់ ឥតមានគូឡើយ នឹងអក្សរនៅខាងចុងវគ្គទាំង៥ ក៏ជាសិថិលឥតមានគូដូចគ្នាដែរ ។ អក្សរឥតគូ ឬអក្សរទោលទាំងនោះគឺ ង ញ ណ ន ម យ រ ល វ ស ហ ឡ អំ ។

---

## ៤ – ព្យញ្ជនៈបន្ថែម

ដើម្បីនឹងប្រើការឲ្យគ្រប់គ្រាន់ក្នុងភាសា បុរាណាចារ្យលោកបន្ថែមព្យញ្ជនៈដោយថែមវណ្ណយុត្តិមូសិកទន្ត និងត្រីសព្ទលើព្យញ្ជនៈខ្លះ ព្យញ្ជនៈទាំងនោះគឺ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ អ៊ ។ ព្យញ្ជនៈទាំងនេះពេលណាមានស្រៈនិស្ស័យ ិ ី ឹ ឺ ើ ភ្ជាប់លើផង គេផ្លាស់វណ្ណយុត្តិ ៉ ៊ ជា ុ ដូចពាក្យៈ បុិន មុឹន វុី បុី សុី ហុឹង អុី ។

---

## ៥ – វណ្ណយុត្តិ

សញ្ញាដែលបន្ថែមលើអក្ខរៈ ដើម្បីនឹងសំរៀងសព្ទវែងជាសព្ទខ្លី ឬសំរៀងសព្ទឲ្យប្លែកពីសព្ទដើម ឬកាត់ពាក្យក្នុងប្រយោគជាសង្កាត់ដើម្បីឲ្យលះសេចក្តី ហៅថាវណ្ណយុត្តិ ។ វណ្ណយុត្តិទាំងឡាយគឺ បន្តក់ ( ់ ) មូសិកទន្ត ( ៉ ) ត្រីសព្ទ ( ៊ ) សំយោគសញ្ញា ( ៎ ) របាទ ( ៌ ) អស្តា ( ៏ ) ទណ្ឌឃាត ( ៍ ) វិសជ្ជនីយ ( ះ ) កុក្កុដនេត្រ ( ៈ ) កាកបាទ ( + ) វង់ក្រចក ( () ) អត្តន្តរ ( “..” ) លៈ ( ។ល។ )

(មកពីពាក្យបេយ្យាលៈ គេយកតែអក្សរ ល ខាងចុង) គោមូត្រ ឬបរិយោសាន ( ៚— ) ខណ្ឌ ( ៕ )

---

## ៦– វិធីប្រើវណ្ណយុត្តិ

បន្តក់ – សញ្ញានេះ សំរាប់ដាក់ថែមលើតួប្រកប ដែលព្យាង្គពាក្យកើតឡើងពីស្រៈ អ នឹងស្រៈ អា ហើយកាត់ស័ព្ទវែងជាស័ព្ទខ្លី ដូចពាក្យៈ ចង ស័ព្ទវែង, ចង់ ស័ព្ទខ្លី; ចាក ស័ព្ទវែង, ចាក់ ស័ព្ទខ្លី, ឃាត ស័ព្ទវែង, ឃាត់ ស័ព្ទខ្លី . . . ឯអក្សរជាតួប្រកបរបស់ព្យាង្គពាក្យ ហើយទទួលសញ្ញាបន្តក់ ( ' ) បានមានតែអក្សរទាំងនេះ ក ង ច ញ ត ន ប ល ស ។ អក្សរក្រៅពីនោះទៅ ទោះកាត់ស័ព្ទវែងជាខ្លីក៏ដោយ មិនដែលទទួលវណ្ណយុត្តិបន្តក់ ( ' ) ឡើយ ដូចពាក្យៈ ជខ បថ សព្វ កព . . . ប៉ុន្តែបើពាក្យណាដែលចេញមកពីបាលីឬសំស្ក្រឹត ទោះអក្សរដែលត្រូវទទួលបន្តក់ ( ' ) បាន ក៏ពុំត្រូវដាក់បន្តក់ ( ' ) ឡើយ ដូចពាក្យៈ កុសល ផល លាមក ធនធាន ជន សត្វ វត្ត ក្សេត្រ ។





មូសិកទន្ត – សញ្ញានេះ សំរាប់ថែមលើអក្សរនៅដើមព្យាង្គពាក្យ កាលណាពាក្យនោះគ្មានព្យាង្គឯទៀតបន្ថែមមក ឬព្យាង្គនោះពោលគឺដាច់តែឯង ដូចពាក្យ ប៉ុន្តែ ប៊ុណ្យហ៊ីន ម៉ក់ ញ៉ាំ ញ៉ី បើកាលណាមានស័ព្ទព្យាង្គដើម ឬតួអក្សរដើមបន្ថែមមក មិនត្រូវដាក់មូសិកទន្ត (") ឡើយ ដូចពាក្យៈ ប្រមោយ ស្រវឹង បម្យា បម្រែក ប្រមាថ សង្កាត ក្នុង ទ្រឹម ច្តុ ត្តាត .... ។

ត្រីស័ព្ទ – វិធីប្រើវណ្ណយុត្តិត្រីស័ព្ទ មានលំនាំដូចគ្នានឹងមូសិកទន្តដែរ ដូចពាក្យៈ ទ្រហ៊ឹង ត្រហា វិហារ ពហាន ។ ស៊ី ហ៊ុងត្រៀក ស៊ុត ហ៊ាន ស៊ុន ស៊ើបការ ... ។

សំយោគសញ្ញា – វណ្ណយុត្តិនេះ សំរៀនសព្ទបាលី ឬសំស្ក្រឹតមកជាសព្ទខ្មែរ ។ ឧបមាដូចពាក្យៈ (ភយ) ភ័យ; (ជយ) ជ័យ; (វយ, ក្សយ) វ័យ, ក្ស័យ; (ពន្ធ) ព័ន្ធ; (ពទ្ធ) ព័ទ្ធ; (យន្ត, យន្ត្រ) យ័ន្ត, យ័ន្ត្រ; យន្ត (យន់), (សម្បទ) សម្ប័ទ; សម្បត្តិ; (បច្ចយ); បច្ច័យ (អាលយ) អាល័យ; (សមយ) សម័យ; (សំសយ) សង្ស័យ; (ហទយ, ហឫទយ) ហទ័យ, ហឫទ័យ ។

សញ្ញានេះប្រើទូវពាក្យខ្មែរខ្លះដែរ កាលណាពាក្យនោះមិនពេញលេញ ជាពាក្យកើតមកពីស្រៈ អ ឬ អា ហើយអក្សរ រ ជាតួប្រកប ដូចពាក្យថាៈ ជ័រ ញ័រ ទំព័រ ទទីទ័រ ព្រឺព្រ័រ សាស៍ន័ព័រ ញញាក់ញញ័រ ... ។

របាទ – សញ្ញានេះជំនួស រ កាលណា រ ជាជំនួសតួអក្សរតម្រួត ។ របាទ (៌) ជាវណ្ណយុត្តិសំរាប់ដាក់ទូវពាក្យសំស្ក្រឹតក្លាយមកពីបាលី ។ ជាធម្មតា តួអក្សរណាដែលពុំសូវប្រើជាជើងជាគ្រាក់ តួតម្រួតអក្សរនោះផ្លាស់ជារបាទ ។ បើតួអក្សរណា



ធ្លាប់ប្រើ ក្រវាត់ក្នុងជើងជើង គួតម្រួតអក្សរនោះផ្លាស់ជាក្រវាត់ ។ គួតម្រួតផ្លាស់ជា រ ក៏បាន ដូចមានពាក្យទាំងនេះជាបែបយ៉ាង ៖

ណ្ណ = ណ៌, ម្ម = ម៌, ត្ត = ត៌, ត្ក = ត៌, ពណ្ណ = ពណ៌, ធម្ម = ធម៌, តក្ក = តក៌, បុញ្ញ = បុញ៌, បរិបុណ្ណ = បរិបូណ៌ = បរិបូរណ៍ ។

មានអក្សរខ្លះដែលធ្លាប់មានជើងជើងក្រវាត់ ជាប់ដោយសញ្ញាបោខ្លះ ក៏មានដែរ ដូចពាក្យៈ កក្កដ ជា កក៌ដ; វិសជ្ជនីយ ជា វិសជ៌នីយ, មគ្គុទ្ទេស ជា មគ៌ុទេស, មគ្គ ជា មាគ៌, មារយាទ ជា មាយ៌ាទ ។

កំណត់កត់សំគាល់ - ក្ក = ក្រ, គ្គ = គ្រ, ទ្ទ = ទ្រ, ស្ស = ស្រ, ដូចពាក្យៈ បក្ក = បក្រ, ខត្ត = ក្សេត្រ, បុត្ត = បុត្រ, សមុទ្ទ = សមុទ្រ... ប៉ុន្តែតួអក្សរដទៃពីរតួ ដូចពោលខាងលើ នេះមិនផ្លាស់តួតម្រួតជា "រ" ឡើយ ។

អស្តា– សញ្ញាអស្តា ប្រើដាក់តែលើអក្សរ ក និង ជ ហើយ ក និង ជ នោះជាពាក្យនិបាត គឺពាក្យនោះមិនមែនជា នាម ជាគុណនាមឬជាកិរិយាស័ព្ទ ដូចពាក្យថា: ពោះហោមដូច ម្តេច ក៏មិនស្តាប់ ។ អ្នកបេះផមិដ៏ប្រសើរ រមែងរួចចាកពី អបាយភូមិ ។ ប្រសើរដ៏ឧត្តម ។

ក្នុងពាក្យឧទានស័ព្ទ គឺពាក្យថាដោយភ្ញាក់ផ្អើល សញ្ញា នេះ មានប្រើខ្លះដែរ ដូចពាក្យ: ឱហ៎! ឱន៎! នុ៎ះហ៎ ប្អូន៎! ។

ទណ្ឌឃាត– និងបដិសេធតួអក្សរលើសពីការ គេដាក់ ទណ្ឌឃាត: រ័តន៍, ពោធ៍, ពេទ៍, ប្រយោជន៍: . . ។

វិសជ្ជនីយ – សញ្ញានេះប្រើជំនួសខ្យល់ "ស" ស័ព្ទខ្លះ: នេះ, ព្រោះ, ជិះ.... ។

កុក្កុដនេត្រ– សញ្ញានេះ សម្រាប់ប្រើផ្តើមសេចក្តី ។

កាកបាទ– សម្រាប់ប្រើពាក្យឧទានសព្ទ និងពាក្យ វិសេសនបព្វនាមខ្លះ ដូចពាក្យថា: ច៎ះ! ចា៎! នុ៎ះ ។

វង់ក្រចក – សញ្ញាវង់ក្រចកសំរាប់ដាក់គៀបពាក្យណា ឬឃ្លាណាមួយ ដែលមិនមានទាក់ទងនឹងបូលក្នុងអត្ថបទនោះទេ គ្រាន់តែជាស័ព្ទពន្យល់ពាក្យណាមួយ ដែលមានក្នុងអត្ថបទនោះៗ ដូចពាក្យថា: បិតាខ្ញុំអញ្ជើញទៅប្រទេសថៃឡង់ដ៍ (ប្រទេសសៀម) តាំងពីខែមេសាម៉្លេះ ៗ

អព្ភន្តរៈ – សញ្ញាអព្ភន្តរៈ សំរាប់ដាក់គៀបឃ្លាណា ដែលមានសារប្រយោជន៍ច្រើន ឬ ឃ្លាណាដែលអ្នកនិពន្ធចង់ឲ្យអ្នកអានយកចិត្តទុកដាក់ប្រឹងអានឃ្លានោះជាង ដូចពាក្យថា ខេមរជនយើងដឹងគ្រប់គ្នាថា "ចេះពីរៀន មានពីរក" ប៉ុន្តែមិនមានជនណាមួយ ខំអនុវត្តតាមពាក្យចំនៀមនោះសោះ ៗ

ល: ៗ ល ៗ – សញ្ញាល: (ៗ ល ៗ) នេះ សំរាប់ប្រាប់ថា ពាក្យដែលគេរាប់រៀបនោះ មិនទាន់អស់ទេនៅមានតទៅទៀត ៗ

គោមូត្រ ឬ បរិយោសាន – សញ្ញានេះ សំរាប់បញ្ចប់សេចក្ដីថា ស្រេចឥតមានតទៅទៀត ៗ

ឃណ្ឌា – សញ្ញាខណ្ឌនេះ សំរាប់ដាក់សេចក្តីសង្កាត់ៗ ដើម្បីធ្វើសេចក្តីនោះឲ្យល្អស្អាត ។

---

## ៧ – អក្សរព្យញ្ជនៈផ្លាស់ប្តូររូប

តួអក្សរផ្លាស់ប្តូររូប កើតឡើងអំពីពាក្យបាលី ដែលក្លាយទៅជាពាក្យសំស្រ្កឹត ពាក្យទាំងនោះខ្មែរប្រើទាំងបាលីទាំងសំស្រ្កឹតៗ ន័យរបស់ពាក្យដូចគ្នា ។ ស័ព្ទនិងរូបអក្សរដូចគ្នា ។ តួផ្លាស់ប្តូររូបទាំងឡាយនោះ នឹងសំរេចជាក្បួនដាច់ស្រេចពុំបាន មានតួខ្លះផ្លាស់ខុសរបៀបក៏មាន ប៉ុន្តែការផ្លាស់តួជាញឹកញយនោះ ដូចមានពាក្យឧបមាទាំងនេះ: អក្ខរៈ ផ្លាស់ជាអក្សរ, យក្ខៈ ជាយក្ស, រុក្ខៈ ជាព្រឹក្ស, សិក្ខា ជាសិក្សា, ខត្តៈ ជាក្សត្រ, ខេត្តៈ ជាក្សេត្រ, ខេមៈ ជាក្សេម, ខណៈ ជាក្សណៈ, ខីរៈ ជាក្សីរ, និច្ចៈ ជានិត្យ, កិច្ចៈ ជាក្រឹត្យ, អាទិច្ចៈ ជាអាទិត្យ, វិនិច្ឆ័យ ជាពិនិស្ច័យ, អច្ឆរិយៈ ជាអស្ចារ្យ, បច្ឆិមៈ ជាបស្ចិម, វិជ្ជា ជាវិទ្យា, វេជ្ជៈ ជាវេទ្យ, សម្មោជ្ជៈ ជាសម្មោទ្យ សម្កោទ្យ, មជ្ឈិមៈ ជាមធ្យម, ឈានៈ ជាធ្យាន, វេជ្ឈៈ

ជា ជេស្ឋ, អធិដ្ឋានៈ ជា អធិស្ឋាន, ព្រះឱដ្ឋៈ ជា ព្រះឱស្ឋ ឋិតៈ ជា ស្ថិត, ឋានៈ ជា ស្ថាន, ថនៈ ជា ស្តន, ព្រះហត្ថៈ ជា ព្រះហស្ត, រដ្ឋៈ ជា រាស្ត្រ ។ អត្ថៈ ជា អាថ៌ . . . បត្តៈ ជា បត្រ, បុត្តៈ ជា បុត្រ, រត្តិ ជា រាត្រី, មេត្តា ជា មេត្រី ។ សមុទ្ទៈ ជា សមុទ្រ, កទ្ទបទៈ ជា កទ្របទ, វេស្សវណៈ ជា វៃស្រវណ, ធម្មៈ ជា ធម៌, មគ្គៈ ជា មាគ៌, បុព្វៈ ជា បូព៌, បរិបុណ្ណៈ ជា បរិបូណ៌ ឬ បរិបូរណ៍, បុណ្ណមី ជា បូណ៌មី, គព្ភៈ ជា គភ៌, ទុគ្គតៈ ជា ទុគ៌ត ឬ ទុរគត ។

## ៨- វិធីស្វាធ្យាយន៍បាំមាត់

ក្ខ ផ្លាស់ជា ក្ស, ច្ឆ ផ្លាស់ជា ក្ស, ច្ឆ ផ្លាស់ជា ស្ច; ជ្ឈ ផ្លាស់ជា ឲ្យ, ជ្ឈ ផ្លាស់ជា ធ្យ, ដ្ឋ ផ្លាស់ជា ស្ឋ; ថ ផ្លាស់ជា ស្ថ ។ ក្ក កម្រែកជា ក្រ, ត្ត កម្រែកជា ត្រ, ទ្ទ កម្រែកជា ទ្រ ។ ម្ម កម្រែកជា ម៌, ណ្ណ កម្រែកជា ណ៌, ព្វ កម្រែកជា ព៌, គ្គ កម្រែកជា គ៌, ទ្ទ កម្រែកជា ទ៌, ក្ក កម្រែកជា ក៌ ។

មានពាក្យខ្លះកើតពីអក្សរ វ និង ព ផ្លាស់ប្តូរគ្នា ដូចពាក្យ ថាៈ វចៈ វចា ជា វាក្យ ឬ ពាក្យ, វេលា វិលា ជា ពេល,

## ១៤ — ថ្នាក់ មជ្ឈិមដ្ឋាន ឧត្តមដ្ឋាន

វនៈ ជាពន (ព្រៃ), វរៈ ជា ព្រះ, វ្រឹក្សៈ ជា ព្រឹក្ស, វិសៈ ជា វិស្ស ឬ ពិស្ស, វិសាខៈ ជា ពិសាខ, វ្រហស្បតិ ជា ព្រហស្បតិ, ទក្សិណៈ ជា ទក្សិណ, ហេមវន្តៈ ជា ហេមពន្ត... ។

ពាក្យខ្លះទៀតដូចៈ សត្តៈ ជាសត្វ, សតវស្ស ជា សតវក្ស ឬ វក្ស៌, បៀវស្សៈ ជា បៀវក្ស... ។

---

### ៩ — វណ្ណយុត្តិ — មេសូត្រ (ព្រហ្មគីត)

អ្នកអើយរីសញ្ញា ត្រូវសិក្សាបេះឲ្យមុត
ឲ្យស្គាល់គ្រឿងវណ្ណយុត្តិ ចូរស្វាហ៍គិតរំពឹង ។

( ់ បន្តក់ )

សញ្ញាមួយនោះណា រាងរូបាទ្រង់ដូចស្ទឹង
បន្តក់វណ្ណយុត្តិហ្នឹង កាត់ស័ព្ទវែងជាស័ព្ទខ្លី ។

( ៉ មូសិកទន្ត )

ស្ទឹងពីរដាក់ទាំងគ្នា លើអក្សរប្រែសំដី
ឈ្មោះមូសិកទន្តី ចេញកណ្ដុរចូរចាំទុក ។

( ័ សំយោគសញ្ញា )

វណ្ណយុត្តិមួយនោះនៃ  កង៏បមេយ្យដូចជាក្អុក
តដសារ “ង” ទៅមុខ  ហៅថាសំយោគសញ្ញា ។

( ៌ របាទ )

របាទជាវណ្ណយុត្តិ
គួរសន្មតជំនួស “រ”
ទ្រង់ទ្រាយក្រងក់ “ង”
ដូចលំនាំកក្រសារ ។



( ៏ អស្តា )

សញ្ញាមួយវិញនោះ  អស្តាស្នោះកងកាយា
អ្នកប្រាជ្ញបញ្ញត្តថា  ឲ្យប្រើលើ “ដ” និង “ក” ។

( ៍ ទណ្ឌឃាត )

ទណ្ឌឃាតសម្រាប់បង់  តួមួយអង្គនៃអក្ខក
ដែលលើសពីស័ព្ទថា  តាមគម្រោគគេតពោល ។

# ១៦ – ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

( ះ វិសជ្ជនីយ )

វិសជ្ជនីយស-ញ្ញានេះត្រូវសព្ទជាអះ ដូចប្រើពាក្យ "ពោះ" "វះ" "មោះ" "សោះ" "ប៉ោះ" សឹងក្បៀលពីរ ៗ

( ៝ កុក្កុដនេត្រ )

សញ្ញាវង់ក្អកមាន់ ចូរកុំភាន់ក្នុងដួងវៃ
អ្នកប្រាជ្ញលោកកែវ ទុកជាដើមផ្ដើមសេចក្ដី ៗ

( + កាកបាទ )

កាកបាទរាងជើងក្អែក ជាចំណែកសញ្ញាគោល
បិតលើពាក្យពំនោល ដូចជា ចា៎ះ ទុ៎ះ ណា៎នែ ៗ

( () វង់ក្រចក )

ពាក្យខ្វះគួរបដិសេធ តែដោយហេតុលុបមិនបាន
ធ្លោះហើយទុកឲ្យមាន ដាក់នៅក្នុងវង់ក្រចក ៗ

( «...» អត្ថន្ទ្រៈ )

សញ្ញាជាក្រោយនេះ នាមជាអត្ថន្ទ្រី
ប្រត្យ័ក្សពាក្យក្នុងធ្វី ដែលត្រូវឃើញយល់ជាក់ស្ដែង ៗ

( ។ល។ លៈ )

មាតិកាសំដែងវែង　　គេចាចែងទុកលៃពាក
ដាក់ប្រួមពាក្យនោះមក　　តំណាងជាសញ្ញាលៈ ។

( ៚ — បរិយោសាន )

បរិយោសានសោត　　ឬគោមូត្រចប់សំដី
សំដែងរឿងអស់　　ចូរយើងដឹងដោយបដំពេភីរ ។

( ។ ខណ្ឌ )

រីខណ្ឌសញ្ញាកាត់　　ជាសង្កាត់ចាកស្នាក់ស្ទើរ
ឲ្យសេចក្ដីប្រសើរ　　ឯរូបភាពដូចឈើត្រាន ។

( - យតិភង្គ )

សញ្ញាជាបណ្ដាប់　　ក្រោយសំរេចមួយនេះឯង
ភ្ជាប់បាទកាព្យចាចែង　　ដែលព្យាង្គបែកចេញពីគ្នា ។
រីឈ្មោះសញ្ញានេះ　　ចូរចាំចុះកុំគង្វា
យតិភង្គនាមា　　ដកាបទៅកុំបំភ្លាយ ។

## ១០— មុខងារនៃអក្សរ

ពាក្យដែលយើងនិយាយមួយម៉ាត់ៗ ទោះពាក្យមានតួអក្សរប្រកបក្តី ពាក្យគ្មានតួអក្សរប្រកបក្តី ហៅថាព្យាង្គ ព្យាង្គដែលមានអក្សរជាតួប្រកបសម្រាប់ព្យាង្គនោះ គឺជាទីផ្លាស់ប្តូរតួប្រកបពុំបានឡើយ ។ ឧបមាដូចពាក្យ: មុខ-មគ្គ-សព្ទ សុខ-ប្រាប-ទើប...: នឹងសរសេរ: មុក-មាក់-សប់-សុក-ប្រាព-ទើព... ដូច្នេះវិញពុំបានឡើយ ។ ភាសាខ្មែរប្រជុំនៃភាសា ៣ គឺ: ភាសាអ្នកស្រុក, ភាសាបាលី នឹងភាសាសំស្រ្កឹត ។ វេយ្យាករណ៍ចែកមុខងារអក្សរព្យញ្ជនៈដាច់ស្រឡះ នោះអក្សរជាតួប្រកបនូវពាក្យខ្មែរ សឹងជាអក្សរនៅដើមវគ្គគឺ: ក ច ដ ត ប ។ អក្សរប្រកបនូវពាក្យបាលីដែលប្រើក្នុងភាសាខ្មែរ ឬពាក្យសំស្រ្កឹតក្តី សឹងជាអក្សរទី ២ ទី ៣ ទី ៤ ក្នុងវគ្គគឺ: ខគឃ ឆជឈ ឋឌឍ ថទធ ផពភ ។ ឯអក្សរនៅចុងវគ្គ នឹងអក្សរនៅសេសវគ្គគឺ: ងញណនម យរលវ សហឡ ប្រើបានជាតួប្រកបនូវពាក្យខ្មែរ

ពាក្យបាលីនឹងពាក្យសំស្ក្រឹតជាមួយគ្នា ។ ន័យមួយវិញទៀត អក្សរទាំងឡាយដែលចាត់ជាតួប្រកបនូវពាក្យមកពីបាលីឬសំស្ក្រឹត អក្សរទាំងនោះមិនត្រូវមានសញ្ញាបន្តក់ថែមពីលើឡើយ ។ ព្រោះពាក្យនោះមានសព្វគ្រប់ហើយ ដូចពាក្យ : សព សព្វ ផល កុសល ជន ធនធាន ពល ប្រាកដ សន្មត លាមក ជាដើម ។

---

## ១១ -- ព្យាង្គរបស់ពាក្យ

តួអក្សរផ្សំគ្នា ឬតួនឹងស្រៈផ្សំគ្នា កើតឡើងជាពាក្យ ពាក្យទាំងនោះ ពាក្យខ្លះមានព្យាង្គតែមួយ ពាក្យខ្លះមានព្យាង្គ ២ ឬហៅពាក្យពីរព្យាង្គ ពាក្យខ្លះបីព្យាង្គ ពាក្យខ្លះមានព្យាង្គច្រើនទៀត ។ ព្យាង្គទោលឬពាក្យព្យាង្គតែមួយ: ចាស់-នៅ-ទឹក-ថ្ងៃ-លេង ។ ពាក្យពីរព្យាង្គ: លំនៅ-បំណាច-បន្ទា-សណ្តែក ... ។ ពាក្យបីព្យាង្គ: ចម្ប៉ាក់-បន្ទាទូក-កន្ទេះឡង់ ... ។ ពាក្យច្រើនព្យាង្គ: អម្ពិលអំពែក-ទោសានុទោស-ថេរានុថេរៈ-ពជកិច្ចានុកិច្ច។

---

## ១២ - ព្យាង្គតម្រួត

ពាក្យទាំងឡាយមានពាក្យខ្លះកើតឡើងពីព្យាង្គកាយ ខ្លះពីពាក្យតម្រួតៗ ព្យាង្គតម្រួតកើតពីពាក្យពីរព្យាង្គជាធម្មតា, កាលណាព្យាង្គទាំងពីរនោះ ព្យាង្គខាងដើមមានអក្សរប្រកប ហើយអក្សរប្រកបនោះ ជាអក្សរនៅក្នុងវគ្គជាមួយគ្នា នឹងពាក្យព្យាង្គបន្ទាប់ ហើយព្យាង្គទាំងពីរ បើញែកគ្នាចេញព្យាង្គមួយៗ គ្មានស័ព្ទប្រែ បើប្រែបានក៏ប្រែខុសសំដៅដូចពាក្យថា: សន្ទូច, បណ្ដើរ.. បើញែកថា សន់-ទូច, បន់-ដើរ នោះពាក្យនិមួយៗ ឥតស័ព្ទថាជាអ្វីៗ នឹងតម្រួតពាក្យលុះតែអក្សរប្រកបរបស់ព្យាង្គដើម នឹងអក្សរព្យាង្គបន្ទាប់នៅត្រូវលំដាប់គ្នា គឺថាអក្សរទី ១ នៅលើទី ២, អក្សរទី ៣

នៅលើទី៤, អក្សរទី៥ នៅលើអក្សរទាំង៤ ខាងដើមនៃវគ្គ ដូចពាក្យ ភិក្ខុ - ព្យញ្ជ (ន៍) - អង្ករ - សង្ខារ - បង្គាប់ - សង្រៀម - ចញ្ចឹម - បញ្ឈឹម មជ្ឈិម - ដណ្ដើម - កណ្ដួប - កន្ទាំង ... ។



ឯអក្សរក្នុងពួកសេសវគ្គគឺ: យរលវ សហឡអ បើត្រូវពាក្យត្រួតនោះទឹងនៅក្រោមតួណាៗបាន ដូចពាក្យ: អង្វរ - ពន្យល់ - បន្សាត់ - បន្លា - ពន្រី - បណ្ហា - បញ្ហា ... ។

## ១៣ - សម្លេងអក្សរ អឃោសៈ - ឃោសៈ

អក្សរដែលមានសម្លេងតឹងហៅថា អឃោសៈ អក្សរដែលមានសម្លេងធូរ ឬបំឡេងធំហៅថា ឃោសៈ ។ សញ្ញាដែលសំពប់បន្ថែមលើតួព្យញ្ជនៈ ង ញ ប ម យ រ ល វ ស ហ ឡ អ ដើម្បីប្រែឲ្យគ្រប់គ្រាន់ក្នុងកាហ នោះកាលណាព្យាង្គពីរ ហើយព្យាង្គដើមមានស័ព្ទជាអឃោសៈ ឬជាឃោសៈ ព្យាង្គខាងចុងក៏នៃសម្លេងទៅ

តាមព្យាង្គដើមមិនបាច់ថែមវណ្ណយុត្តិឡើយ ដូចពាក្យៈ សង្ហាត-សម្-ប្រមាទ - សមា - ចម្បា - សាលា - កុមារ - ប្រវែង ចម្ងាយ - សន្យា-សន្ធត - សញ្ញា - ប្រាជ្ញា - វិហារ - ពាហាន - ដំហាន - ដំហារ ... ។

តួព្យញ្ជនៈផ្សំដែលហៅថាជើងនោះ ជើងអក្សរដែលយកទៅផ្សំនឹងសម្លេងទៅតាមតួលើ តាមដោយស័ព្ទសម្លេងជា ឃោសៈ ឬជាអឃោសៈ មិនបាច់មានវណ្ណយុត្តិដូចគ្នា ។ ចូរមើលព្យញ្ជនៈផ្សំទាំងនេះ ក្ក គ្ក ខ្ក ឃ្ក ក្ខ គ្ខ ខ្ខ ឃ្ខ ឈ្ខ ច្ច ជ្ច ច្ច ជ្ច ខ្ក ខ្ក ខ្ប ខ្ត ស្ខ ស្ត ក្រ គ្រ ប្រ ប្រ ស្រ គ្រ ទ្រ ព្រ ម្រ ... ក្ខង, កើតឃ្លង់, គ្ខគា ... ។

## ១៤ — នាមក្រិត - កិរិយាក្រិត

អក្សរជាតួទីងគ្នាក្ខងវគ្គ - ពាក្យយារចេញពីពាក្យដើម ឬបែកចេញពីពាក្យដើមហៅថាកិតៈ ឬក្រិត ។ ដៅនៃពាក្យទាំងឡាយ សឹងបែកចេញទៅពីតួឯង ឬចេញទៅពីអក្សរជាតួដូចពាក្យៈ ឈ្លួញ បែកចេញទៅជាពាក្យ ចំនួញ , កោស ចេញ

 

ទៅជាខ្នោស, គាបទៅជាឃ្នាប, ចីទៅជាចំណី, ឆ្អិន ទៅជាចំអិន, ធ្ងន់ ទៅជាទម្ងន់, បួស ទៅជាផ្នួស, ពំនួន ទៅជាក្នួន, គិត ទៅជាគំនិត, កាត់ ទៅជាកំណាត់, ទើបទៅជាទំនើប...។ លើកតែពាក្យខ្លះ ដែលវេយ្យាករណ៍ មានអធ្យាស្រ័យឲ្យប្រើដូចពាក្យ: ដើរ ទៅជាថ្មើរ, ត្រង់ទៅជាដម្រង់ ឬតម្រង់, ត្រូវ ទៅជាតម្រូវឬដម្រូវ, ប្រជុំ ទៅជាក្ដុំ... កិរិយាដែលបែកទៅជានាម ហៅថាកិរិយាក្រិត ។ នាមដែលចេញមកពីកិរិយា ហៅថានាមក្រិត ឬហៅថាកិតនាមក៏បាន ។ កិតនាមខ្លះជាកិរិយា ជាក់ជានាម

## ២៤- ថ្នាក់មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន





ដូចពាក្យៈ អ្នកដើរ អ្នករែក អ្នកដេក អ្នកមក អ្នកបេះ អ្នកទៅ សឹងជាកទ្ធិតនាម ។

ជំនុំនៃពាក្យ- ពាក្យដែលយើងនិយាយ កើតឡើង ពីស័ព្ទប្រាំបីយ៉ាង :

១- នាម ។ ២- គុណនាម ។ ៣- កិរិយា ។ ៤- សព្វនាម ។ ៥- កិរិយាវិសេសន៍ ។ ៦- និបាត ។ ៧- ឧទានស័ព្ទ ។ ៨- បរិវារស័ព្ទ ។

# ១៥ - នាម

សំដីដែលបំដែងនូវឈ្មោះ ជាគ្រឿងសំគាល់ឲ្យហៅបាន ដូចពាក្យថា: មនុស្ស-សត្វ-ដី-ទឹក-ខ្យល់-ឈើ-ទន្លេ-សមុទ្រ ។ល។ ពាក្យទាំងឡាយនោះហៅថានាម ។ នាមនាម មានពីរយ៉ាងគឺ: សាធារណនាម ១ អសាធារណនាម ១ ។

## សាធារណនាម

វត្ថុទាំងឡាយ ដែលមាន បែបសណ្ឋានទលាំគ្នាប្រហែលគ្នា ជាសាធារណនាម ដូចពាក្យ ហៅថា "ផ្ទះ" វត្ថុឯណាដែល មានភាព បែបប្រហែលនឹង



# ២៦ – ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

គេហស្ថាននោះហៅថាផ្ទះដូចគ្នា ៗ "ស្រែ" វត្ថុណា មានភាពដូចដី



នោះ ហៅថាស្រែដូចគ្នា ៗ "ខ្លា" សត្វឯណា មានភាពដូចគ្នាហៅថា ខ្លា ៗ "ដើមតាំង" វត្ថុមានភាពដូច ដើមម៉ាំនោះ ហៅថាដើមតាំង.. ៗ

ពាក្យហៅថា ផ្ទះ-ស្រែ-ខ្លា-ដើមតាំង ជាសាធារណនាម ៗ

## អសាធារណនាម

នាមគឺសំរាប់តែមនុស្សម្នាក់ សត្វមួយ ឬវត្ថុមួយផ្សេងម្នាក់ឯង ហៅថាអសាធារណនាមព្រោះនាមនោះមិនបំពោះទូទៅឡើយ ដូចនាមថា: ភ្នំពេញ - មេគង្គ - ក្របេះ - ស៊ីសុវត្ថិ - នរោត្តម . . . ឈ្មោះភ្នំពេញសំរាប់តែក្រុងខ្មែរម្នាក់ឯង, ឈ្មោះមេគង្គសំរាប់តែទន្លេ នៅស្រុកខ្មែរនេះ, ឈ្មោះស៊ីសុវត្ថិ-នរោត្តម សំរាប់តែរូបស្តេចដែលសុគតហើយនោះ ៗ

# ១៦- លិង្គរបស់នាម

នាមនាមទាំងឡាយមានភេទផ្សេងគ្នា ភេទរបស់នាមនោះ ហៅថាលិង្គ ។ លិង្គមាន ៣ យ៉ាងគឺៈ បុំលិង្គ (បុំងលឹង), ឥត្ថីលិង្គ, នបុំសកលិង្គ ។ បុំលិង្គគឺភេទសំរាប់មនុស្សប្រុស សត្វឬវត្ថុឈ្មោល, ឥត្ថីលិង្គ គឺភេទសំរាប់សំគាល់មនុស្សស្រី សត្វឬវត្ថុញី, នបុំសកលិង្គជាភេទសំគាល់មនុស្ស សត្វឬវត្ថុខ្ទើយ គឺភេទមិនមែនជាប្រុសឬជាស្រី ជាឈ្មោលឬញី ។ តាមដោយបញ្ញត្តិនៃក្បួនហោរ នាមរបស់មនុស្សប្រុស អក្សររបស់មន្ត្រីសុទ្ធជាបុំលិង្គ ។ នាមរបស់មនុស្សស្រី នាមរបស់ស្រុក-ភូមិ-នគរ-វត្ត-ខេត្ត-សុទ្ធជាឥត្ថីលិង្គ ។ នាមរបស់មនុស្សខ្ទើយជានបុំសកលិង្គ ។ ឯកនៃក្បួនខ្លះ វត្ថុដែលជាគ្រឿងលេងសុទ្ធជាឥត្ថីលិង្គ ដូចអង្គុញ់-មេប្រុក... ។

លិង្គប្រើជាពាក្យសំរាប់ប្រុសស្រី ដូចពាក្យថាៈ មា-ឪ-តា-ពូ-ធំ-អយ្យកោ-បិតុលា-កុមារ-យក្ស-យក្ខ-ចោរ-ភរី-ភរិខ-ភិក្ខុ-សាមណេរ-គោ-ពានរ... ជាពាក្យសំរាប់បុំលិង្គ ។ ដូចពាក្យ

ហៅថា ម៉ង - ម៉ែ - យាយ - អយ្យិកា - មាតុច្ឆា - កុមារី - យក្សិណី, (យក្ខិន) - ទេវី - ករិណី - ភិក្ខុនី - ភិក្ខុណី - សាមណេរី - នារី - វានរី ព្រាហ្មណី... ជាពាក្យសំរាប់ឥត្ថីលិង្គ ។

## ១៧ វចនៈ

វចនៈ ជាពាក្យសំគាល់វត្ថុតែមួយ ឬវត្ថុច្រើន ។ ពាក្យដែលតំណាងវត្ថុតែមួយហៅថាវចនៈ ។ ពាក្យដែលតំណាងរបស់



ច្រើនហៅថាពហុវចនៈ ។ ក្នុងវចនៈទាំងពីរយ៉ាងមិនជាការសំខាន់ពេកឡើយ, កាលណាគេចង់ប្រើជាពហុវចនៈ គេផ្ទួនពាក្យ ឬ ថែមពាក្យទៀតដូចជា: ប្រុស ៗ ស្រី ៗ ក្មេង ៗ កូនទាំងឡាយ ឈើទាំងឡាយ អស់ទាំងសត្វ ។ តែមានពាក្យខ្លះដែលចេញពីបាលី ឬ សំស្ក្រឹត មានសំគាល់វចនៈខ្លះដែរ ដូចពាក្យថា: ភិក្ខុ - ភិក្ខូ, យក្ស - យក្សា . . . ភិក្ខុ (ឯកវចនៈ), ភិក្ខូ (ពហុវចនៈ), យក្ស (ឯក) យក្សា (ពហុ.) ។

## ១៨ — គុណនាម

ពាក្យដែលសំដែងលក្ខណៈរបស់នាម ឬគ្រឿងនាមឲ្យមានបទ ដូចពាក្យថា: ថ្មរឹង-មនុស្សចាស់-ដែកស៊ុត-កែវស្រួយ... រឹង ចាស់ ស៊ុត ស្រួយ ប្រាប់លក្ខណៈ



ថ្ម-មនុស្ស-ដែក-កែវ ហៅថា គុណនាម ។ នាមនាមមាន លក្ខណៈសម្រេចហើយ ហៅថា គុណបទ ។ គុណនាមមានបីយ៉ាងគឺ: បកតិគុណនាម ១, វិសេសគុណនាម ១, អតិវិសេសគុណនាម ១ ។

### បកតិគុណនាម

គុណនាមសំដែងលក្ខណៈតាមលំអានជាប្រក្រតី ដូចពាក្យថា: ភ្នំធំ-ទន្លេវែង-ស្លឹកស្ដើង-វង់មូល-ដីខ្ពស់-សេះធាត់-សំពត់ម៉ដ្ឋ ស្រមោចតូច-អាវខ្លី-ក្ដារក្រាស់-ប្រាក់រៀលសំប៉ែត-ក្មេងទាប គោស្គម-មនុស្សកំសោយ-ដានប្រសប់-កប៉ាល់លឿន-សក់ស្កូវ·

## ៣០ – ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

ផ្ទៃធំ - ខ្ទុរស្រគាល - ព្រានពោត - ភ្លើងក្តៅ - ទឹកត្រជាក់ - ខ្យល់រងា - ត្បូងភ្លឺ - គុរលោង ឆ្កែកាប ... ៗ

### វិសេសគុណនាម



គុណនាមដែលសំដែងលក្ខណៈរបស់នាមឲ្យវិសេសឡើង ដូចពាក្យថា: ផ្លូវត្រង់ជាង - ឆ្កែនេះកាចជាង - គោនេះធំជាង - មនុស្សប្រសប់ជាង - កាំបិតមុតជាង - ឈើខ្ពស់ប្លែក ... ៗ

### អតិវិសេសគុណនាម

គុណនាមដែលសំដែងលក្ខណៈឲ្យវិសេសបំផុត ដូចពាក្យថា: ប័ន្ទសផង - កំពោរសក្បុស - ស្បែកខ្មៅបង់ - កាំបិតមុតណាស់ - គោយឺតណាស់ - កូនមនុស្សព្រហ៍ណាស់ ... ៗ

— —

## ១៩ - កិរិយាស័ព្ទ ឬកិរិយា

ពាក្យពោលនូវអំពើធ្វើ ឬពោលនូវដំណើរជាអ្វី ហៅថា កិរិយាស័ព្ទ ដូចពាក្យថា: ដើរ - ឈរ - អង្គុយ - ដេក - ស៊ី - ផឹក - ងូត - លាង - និយាយ - ស្តី - ហៅ - យំ - ស្រែក - វាយ - ដំ - ជីក - គាស់ - ឈូស - ចាំង - ឆ្ការ - វាស់ - កាប់ - កាត់ - អាន - សរសេរ - តែង - ធ្វើ ... ។



ពាក្យជាកិរិយាស័ព្ទ មានប្រធាន កាលណាគេបង្កើតជាប្រយោគដូចពាក្យថា: ខ្ញុំដើរ... ខ្ញុំជាប្រធានរបស់កិរិយាដើរ ។ យើងដេក - គេឈូស - វាធ្វើ - កូនសិស្សសរសេរ - អ្នកស្រែឆ្ការ ... ។ កិរិយាមានពីរយ៉ាង គឺ: សកម្មកិរិយា ១, អកម្មកិរិយា ១ ។

### សកម្មកិរិយា

គេហៅថាកម្មគឺពាក្យដែលប្រើសំរាប់បំពេញអំពើរបស់កិរិយា គេហៅថាសកម្មកិរិយា គឺកិរិយាដែលត្រូវមានពាក្យមកបំពេញអំពើទើប



គ្រប់គ្រាន់ដូចពាក្យថា: ខ្ញុំឈូសឈើ, គេទាញសំពត់, អ្នកនេសាទស្ទូចត្រី, ចោរលួចទ្រព្យ... ។ ឈើ-សំពត់-ត្រី-ទ្រព្យ ជាកម្មរបស់កិរិយា ឈូស-ទាញ-ស្ទូច-លួច ។

## អកម្មកិរិយា

កិរិយាដែលមានអំពើគ្រប់គ្រាន់នឹងខ្លួនឯងហើយ ហៅថា អកម្មកិរិយា ដូចពាក្យថា: ខ្ញុំកើត, យើងទៅ, វាស្លាប់, កប៉ាល់ចេញ, ក្មួយខ្ញុំមក, ប្អូនខ្ញុំដល់, ឈឺងាប់, សត្វហើរ, គេឈរ, ទឹកហូរ, គោបោល,



ឆ្កែលូ, គោរោទ៍, ព្រាបថ្ងូរ, ខ្លាគ្រហឹម, សំពត់ជ្រុះ, លោកមានប្រសាសន៍... ។

កិរិយាមានឈ្មោះហៅថា ហេតុកិរិយា គឺកិរិយាដែលធ្វើអំពើទៅគេ ដូចពាក្យថា: បង្រៀន គឺធ្វើអំពើទៅគេ ។

កិរិយាហៅថាសុទ្ធកិរិយា គឺកិរិយាដែលធ្វើចំពោះខ្លួនឯង ដូចពាក្យថា: រៀន គឺធ្វើអំពើចំពោះខ្លួនឯង ។

## ២០-វិធីហាត់

ពាក្យមានបន្តក់ – កង់ កត់ កប់ ខ្វល់ ទល់ សក់ យល់ ពន់ ទក់ ធន់ បត់ បង់ បង់ ហត់ ព្រនង់ កំពង់ ពន្យល់ ទំនប់ កញ្ជក់ បង្កង់ ដំទង់ គំរប់ ទំរង់ បំណង់ កន្សល់ បង្អស់ បន្តក់ បំរត់ បន្ទប់ សំណល់ កញ្ចក់ កាត់ ខាត់ សាត់ ចាត់ ផាត់ ភ៊ត់ ហាត់ អាត់ ណាត់ បង្ហាត់ បំបាត់ សំខាន់ សម្លាប់ សំគាល់ កំណាញ់ បន្ទាល់ ក្បាល់ វិនាស់ ប្រញាប់ប្រញាល់ កន្តាល់ អ៊ីវ៉ាន់ រហាត់ បំឡាក់ វ្សភន់ ប្រញាប់ ណាស់ កំចាត់កំចាយ ។

ពាក្យឥតបន្តក់– កល កុសល ផល ភទ្ទ គណ ចក្ក ឆត្ត គជទន្ត ជនបទ ជប ថលបថ កម្មបថ ថលយាន ខណ្ឌ បញ្ញា បញ្ញត្ត បត្តភាគ និមិល ពលកាយ ភក្ត្រ ភត្តកាល

កាលបក្ស ប្រាកដ ប្រយ័ត្ន ប្រកព បក្ខគណនា មណ្ឌប ពមល មាណព រក្ខ រក្ស ក្សត្រ ហរិរក្ស ។

---

## ២១ - សព្វនាម

សព្វនាមជាពាក្យតំណាងនាម ដូចពាក្យថា: ខ្ញុំ, អ្នក, ឯង, វា, គេ, នាង, លោក, ព្រះអង្គ ... ជាសព្វនាម ។

សព្វនាមមានពីរយ៉ាងគឺ បុរិសសព្វនាម ១, វិសេសនសព្វនាម ១ ។

### បុរិសសព្វនាម

បុរិសសព្វនាមចែកជា: បឋមបុរិស:, មជ្ឈិមបុរិស:, ឧត្តម-បុរិស: ។ បឋមបុរិស:គឺ: វា, គាត់, គេ, នាង, លោក, ព្រះអង្គ... ។ មជ្ឈិមបុរិស:គឺជាសព្វនាមសំរាប់ប្រើជំនួសឈ្មោះបុគ្គល ដែលគេកំពុងតែនិយាយទៅរកក្នុងទីចំពោះមុខ ហើយនិយាយមិនចេញឈ្មោះឡើយ យកស័ព្ទនេះជំនួស ដូចពាក្យចំពោះមុខ: ឯង, លោក, អ្នក, នាង, អា, ហង ... តាមពាក្យទាប-ខ្ពស់-កណ្ដាល ។ ឧត្តមបុរិស:គឺ: ខ្ញុំ, ខ្ញុំបាទ, ខ្ញុំឯង, អញ, អញខ្ញុំ, អាត្មាភាព, យើងខ្ញុំ,

យើង ... តាមពាក្យទាប-ខ្ពស់-កណ្ដាល ។ ឧទាហរណ៍: កូនខ្ញុំបាទ អាយុ .. ដឹងក្ដីបន្តិចហើយ ឥឡូវនេះវាទៅរៀនឯសាលា ។ មារបស់ខ្ញុំនៅភូមិឯស្រុកស្រែ គាត់បានឲ្យដំណឹងមកថា: គាត់នឹងមកលេងនឹងខ្ញុំនៅថ្ងៃខាងស្អែក ។



សត្វពាហនៈគឺ : គោ-ក្របី-ដំរី-សេះ, សត្វទាំងនោះធ្វើប្រយោជន៍ឲ្យយើង ចូរយើងថែរក្សាឲ្យល្អ ។ ទេវីម្នាក់ឈ្មោះបទុមកេសរ រត់ចេញពីនគរជាមួយនឹងស្វាមីទៅដល់កណ្ដាលព្រៃ នាងក៏ប្រសូតបុត្រ ។ ហ្វូងយានមកប្រថាប់



ក្នុងបុណ្យនេះ ទ្រង់នឹងយាងមកដោយយានសិវិកា, នាម៉ឺនសព្វមុខមន្ត្រីនៅរង់ចាំថ្វាយបង្គំព្រះអង្គ ។ អ្នកអញ្ជើញទៅកំពត នោះអ្នកនឹងទៅដោយអ្វី ! ។

កាលណាឯងទៅនៅទីក្រុង ឯងកុំដើរលេងយប់ ឯងកុំមានកៀននឹងមនុស្សអាក្រក់ ។ អាឯងឈ្មោះអ្វី ? អាដែលលួចគេប៉ុន្មានដងហើយ ? អាឯងមានប្រពន្ធកូនឬទេ ? ។ នៅថ្ងៃទំនេរពីថ្ងៃរៀន, ខ្ញុំច្រៀតទៅសួរឪពុកម្ដាយរបស់ខ្ញុំ ។ ល្ងាចនេះគេនិមន្តអាត្មាភាពទៅទេសនា ។ យើងពល់រូប តែងតែមានសេចក្ដីស្ងប់ជាធម្មតានឹងជៀសពុំបាន ។

## វិសេសនសព្វនាម

វិសេសនសព្វនាម គឺជាស័ព្ទសំរាប់ប្រើជាជំនួយនាមនាមមានលំនាំជាបទវិសេសន: ដើម្បីនឹងមិនឲ្យច្រឡំសេចក្ដីក្នុងសង្កាត់នៃប្រយោគមួយៗ ។ វិសេសនសព្វនាម មានពីរយ៉ាងគឺ: វិសេសន-សព្វនាមនិយម១, វិសេសនសព្វនាមអនិយម១ ។ វិសេសនសព្វនាមដែលសំដែងសេចក្ដីដាច់ស្រេចហៅថានិយម ។ វិសេសនសព្វនាមដែលសំដែងសេចក្ដីមិនដាច់ស្រេចហៅថាអនិយម ។

វិសេសនសព្វនាមនិយម: នោះ, នុ៎ះ, ហ្នឹង, នេះ, មាក់, មួយទៀត, ឯនេះ, ឯណោះ: ( Pronom démonstratif ) ។

វិសេសនសព្វនាមអនិយមៈ ឯណា, ដទៃ, ណាមួយ, ផ្សេង, ទៀត, ដូចម្តេច, ពួកខ្លះ, អ្នកខ្លះ, ខ្លះ, ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, អ្នកណា, អ្វី, ឯទៀត ( Pronom indéfini ) ។

វចនសព្វនាមឯកវចនបឋមបុរសៈ វា, គេ, នាង, លោក, ព្រះអង្គ, អា, មេ ... ។ ពហុវចនបឋមបុរសៈ វាទាំងឡាយ, គេទាំងឡាយ, អស់នាង, អស់លោក ... ។

ឯកវចនមជ្ឈិមបុរសសព្វនាមៈ អ្នក, នាង, លោក, ឯង, អា, ហង ... ។

ពហុវចនមជ្ឈិមបុរសសព្វនាមៈ អស់អ្នក, អស់នាង, អស់លោក, ឯងទាំងអស់គ្នា, អាទាំងឡាយ ... ។

វចនឧត្តមបុរសសព្វនាមៈ ខ្ញុំ ( ឯក. ), យើង ( ពហុ. ), យើងខ្ញុំ ( ពហុ. ) ។

វិសេសនសព្វនាមក៏មានវចនៈដូចពាក្យថាៈ នេះ ( ឯក. ), នោះៗ ( ពហុ. ), ណា ( ឯក. ), ណាៗ ( ពហុ. ), ម្នាក់ៗ ( ពហុ. ) ។

# ២២ – កិរិយាវិសេសន៍

កិរិយាវិសេសន៍ជាស័ព្ទបន្ថែមលើកិរិយា ដើម្បីឲ្យកិរិយាមានស័ព្ទវិសេសឡើង ឬប្លែកឡើងទៀត ។ កិរិយាវិសេសន៍បន្ថែមស័ព្ទរបស់គុណនាមឲ្យប្លែកឡើងដែរ ដូចបានអធិប្បាយរួចហើយនៅខាងលើអំពីអតិវិសេសគុណនាមនេះឯង ។ បើកាលណាគេញែកពាក្យក្នុងបទសម្ពន្ធនោះគុណនាមនឹងកិរិយាវិសេសន៍បង្គាប់គ្នាជាបទហើយហៅថាអតិវិសេសគុណនាមក៏បាន ឬហៅញែកពីគ្នាចេញក៏បាន ។

កិរិយាវិសេសន៍ទាំងឡាយគឺ ឆាប់, ណាស់, យឺត, លឿន, មួយៗ, រឿយៗ, ទន្ទើន, ណឹមណុម, បិតបេរ, ស្ទើរ, រើះ; ក្លែត, ក្លាម, ថ្លៃ, គាន់គាប់, ខ្នាន់ខ្នាប់, ញើបៗ, លបៗ, ណេះណោះ, គគាក់គគាំ, ទឹង, នែលនល, ដរាប, នៅ, បណ្ដាប់, បន្ដោក, បន្ដុប, បន្ដិច, បន្ថែម; ប៉ោបៗ, ប៉ុក, ប្រកិត ប្រកឹង, តូង, ប្រូស, ព្រួត, ព្រងើយ; រម៉ាំងរម៉ោក, គ្រេង, ប្រូង, ព្រឹស, ប៉ុង, គ្រាំង, គឹង... ។

ឧទាហរណ៍ៈ ទៅឆាប់, មកក្លាម, ដើរយឺត, មើលខ្ជាន់ខ្ជាប់, ធ្វើមារយាទប្រឹមប្រុម, មានជីវិតឋិតថេរ, ដេញប្រកិត, ប្រកឹងតារ, ដួលគួង. ទៅរម៉ាំងរម៉ោក, រលំគ្រែង, ទៅណេះ, ទៅណោះ. មកជាប, ជម្ងឺពុំទាន់ជានៅឡើយ, និយាយប៉ោចៗ, ផាក់ប៉ុក, រៀបបន្ទុប, អ្នកទិញមកថ្លៃបន្តិចហើយ, ដំរីរត់លឿនស្ទើរ ... ។

---

## ២៣ – វិធីប្រើអាយតនិបាត

អាយតនិបាត មានអត្ថប្រព្រឹត្តទៅតាមចំនង់សេចក្តី ដូចមានតទៅ ៖

អាយតនិបាតទី ១ – "រី" សំរាប់ប្រើជាបទប្រធានឬដើមបទ ។. រីបុណ្យនិងបាប អំពើសុភាព នោះរាំតែងតាម... ។ រីគ្រូបាធ្យាយ ប្រដូចនូវម្តាយ អាពុកឯងហោង ។ រីអំពើជាកុសល ជនគប្បីធ្វើ ។

អាយតនិបាតទី ២– មានអត្ថ ៥ យ៉ាង:

១– "ឲ្យ" សំរាប់ភ្ជាប់កម្មរបស់កិរិយាសកម្ម ។

ឧទាហរណ៍ៈ គេស្តាប់នូវធម៌, សង្ឃសំដែងនូវធម៌ ។ ប៉ុន្តែក្នុងភាសាដែលគេនិយាយជាធម្មតា គេច្រើនកាត់ពាក្យ "នូវ" ដូចគេនិយាយថាៈ គេស្តាប់ធម៌, លោកសំដែងធម៌ ។

២– "កាន់" សំរាប់ភ្ជាប់កម្មទៅកិរិយាសកម្ម ឧ. គេទៅកាន់ផ្ទះ, វាមកកាន់ផ្ទះ ។ ប៉ុន្តែតាមភាសាធម្មតាគេច្រើននិយាយកាត់បង់ដូចថាៈ ខ្ញុំទៅផ្ទះ, គេមកផ្ទះ ។

៣– "ញុំាង" ជាទីទទួលសម្រេចនូវអំពើដែលគេឲ្យធ្វើ, ឧ ពពួកសត្វផង សាហាវយង់ឃ្នង ប្រយ័ត្នញុំាងបាន . . : ព្រះពុទ្ធត្រាស់ដឹងនូវអរិយសច្ច ហើយ ញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង, គ្រូបដៅខ្នានសិស្សញុំាងសិស្សឲ្យរៀន ។

៤– "អស់" ប្រែថាទៅ ហួសដល់, ឧ. គេទៅអស់យោជន៍ទបី, វាទៅអស់យប់មួយ ។

៥– "នឹង" ឬ "ចំពោះ" ទទួលពាក្យដែលគេនិយាយចំពោះខ្លួន, ឧ. ខ្ញុំបាននិយាយនឹងអ្នក, - ចំពោះអ្នក, គេផ្តាំមកនឹងខ្ញុំ ។

## អាយតនិបាតទី ៣- មានអត្ថ ៦ យ៉ាង:

១- "ដោយ" ជាគ្រឿងសម្រេចនូវអំពើ ។. គេធ្វើនូវអំពើដោយកាយ ។ គេកាន់ស៊ីវ ដោយដៃ ។

២- "ដោយនូវ" ឬ "តាម" ឬ "ដោយសារ" ជាផ្លូវជាលំនាំដែលប្លែកពីការសម្រេចនូវអំពើ ។. ព្រះពុទ្ធទ្រង់វៀងដោយនូវតេជះ, ធ្វើតាមពាក្យនៃអញ, វារស់នៅដោយសារសេចក្តីទំនុកបំរុងនៃខ្ញុំ ។

៣- "គឺ" ឬ "ដែល" ជាអ្នកសម្រេចនូវអំពើអំពីខ្លួនឯង ។: ធម៌គឺការៈដែលទ្រទ្រង់, ពាក្យនេះដែលខ្ញុំបានប្រាប់ហើយ, គឺអ្នកឯងមិនត្រូវធ្វើយ៉ាងនេះទៀត, ព្រះសាស្តា គឺអ្នកទាំងឡាយគប្បីឲ្យអត់ទោស ។

៤- "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាហេតុ, ជាចំនង, ជាដំណើរ ។. បានជាគាត់នៅក្នុងទីនោះ ព្រោះតែសក្ការៈ, សត្វលោកមានចិត្តខ្ពស់ឡើងព្រោះលាភ មានចិត្តទ្រោមចុះព្រោះខាតលាភ ។

៥– "មាត្រ" ជាអាការៈ ។. បើបុគ្គល មានចិត្តគិតទោស ប្រទូស្តហើយ ពាលក្តី ធ្វើក្តីៈ ។

៦– "ដោយ" ប្រកបជាមួយ ។. ចូរព្រមព្រៀងដ៏មួយ អទ្ទើ ដោយដំណើរនោះ ។

## អាយតនិបាតទី ៤ – មានអត្ថ ៣ យ៉ាង:

១– "ដល់" ជាទីទទួលនូវអំណោយ ។. ចាយកឲ្យនូវទាន ដល់សង្ឃ, ក្រលំបាកឲ្យផល ដល់អ្នកកំដល ។

២– "ដើម្បី" ឬ "បំរុង" ជាទីធ្វើបញ្ចូន ។: គេបង្គាប់មនុស្សឲ្យក្រាលនូវអាសនៈទាំងឡាយ ដើម្បី ឬ បំរុង ភិក្ខុសង្ឃ, អាពុកធ្វើទៅនូវសំលៀកបំពាក់ទាំងឡាយ ដើម្បីកូន ។

៣– "បំពោះ" ឬ "នឹង" ជាទីត្រូវគេបៀតបៀន ។. អ្នកណាប្រទូស្ត បំពោះ ឬ នឹងមនុស្សដែលមិនប្រទូស្ត ។

## អាយតនិបាតទី ៥– មានអត្ថ ៣ យ៉ាង:

១– "អំពី" ឬ "ចាក" ។. ភ័យ អំពីសេចក្តីស្លាប់, បុគ្គលគប្បីឃាត់នូវចិត្ត ចាកបាប គឺជាបុគ្គលគប្បីលះបង់បាប ។

២ – “ជាង” ជាដែនប្រៀបធៀបឲ្យដឹងថាលើស ឬ ថយ ជាងគ្នា ឧ. សីលជាគុណជាត មានផលច្រើន ជាងទាន ។

៣– “ហេតុ” ឬ “ព្រោះ” ឬ “ព្រោះតែ” ជាទីមូលហេតុ-ដើមចម ឧ. សន្តិភាពនឹងក្លាយកើតព្រម ព្រោះសេចក្តីល្ងង់នាំភាពទន់ឲ្យកើត ។

## អាយតនិបាតទី ៦– មានសព្ទ ៤ យ៉ាងនេះ

១ – “នៃ” ឬ “របស់” ជាគ្រឿងជាប់ដោយម្ចាស់

ឧ. ផ្ទះ នៃអ្នកស្រែ ឬ របស់អ្នកស្រែ ។

២ – “នៃ” ជាគ្រឿងជាប់ដោយពួក-ដោយក្រុម ឧ: ប្រជុំ នៃជនទាំងឡាយ ហ្វូង នៃគោទាំងឡាយ ។

៣ – “នៃ” ជាគ្រឿងជាប់ដោយការសន្មតនឹងដើម ឧ. ភារៈ នៃអគ្គ នឹកុលបុត្តគប្បីធ្វើបានដោយកម្រ, កិច្ចដោយប្រចាំបមិនបានឡើយ ព្រោះភារៈ នៃតាន្ទ្រីព្រះអាទិត្យមានគុណ កាលសង្គ្រោះ ។

៤– "កាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្ដីផ្ដើមចូលមកប្រាប់ហេតុដូចជាបទប្រធានដោយឡែក ៖ កាលដែលទារកកំពុងយំ បិតាចេញទៅហើយ, អ្នកទាំងឡាយចូររង់ចាំក្នុងទីនុះបន្តិចសិន, កាលបើខ្ញុំនិយាយថា៖ អ្នកទាំងឡាយចូរចូលមកចុះចូរមកឲ្យឆាប់ ។

៥– "ជុំគុំ" ឬ "បណ្ដា" ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួម ដែលប្រមូល ៖ បណ្ដាមនុស្សទាំងឡាយ ក្សត្រិយ៍ក្លៀវក្លាបំផុត ។

## អាយតនិបាតទី ៣ – មានអត្ថ ៩ យ៉ាង៖

១– "ក្នុង" ជាទីកំបាំង ៖ គេអង្គុយក្នុងខាងក្នុងនៃបន្ទប់ ។

២– "ក្នុង" ជាទីជ្រួតជ្រាប ឬ លាយគ្នា ៖ ប្រេងស្ថិតនៅក្នុងល្ងទាំងឡាយ, ទឹកដោះស្រស់ស្ថិតនៅក្នុងទឹក ។

៣– "ក្នុង" ជាទីអាស្រ័យ ៖ ត្រីទាំងឡាយនៅក្នុងទឹក ។

៤– “ក្នុង” ជាកាល ជាពេល ឧ. កុសលចិត្ត ជាចិត្ត កើតឡើងហើយមានក្នុងសម័យឯណា ។

៥– “លើ” ឬ “ពួង” ឬ “ត្រង់” ឬ “ឆា” ជាទីនៅ-ទ្រ-ផ្ទាប់-ផ្ទៀតផ្ទែក ឧ. ព្រះដ៏មានព្រះភាគគង់ហើយលើអាសនៈ ដែលគេក្រាលហើយ, ពោមចាំងឡាបពួជព្រែង ឬ ត្រង់ព្រែង ។

៦– “ឆាកាល” ឬ “កាលបើ” ឬ “កាលដែល” ជាសេចក្ដីដែលតូចប្រហែលដូចជាបទប្រធាន ឧ. ឆាកាល ព្រះអាទិត្យអស្ដង្គតហើយ ព្រះចន្ទរះឡើង, កាលបើយ៉ាំនេះមាន មានតែយើងកុះ៧, កាលដែលមាណពនោះនិយាយច្រើន ៗ ទៅ សរីរៈទាំងអស់នៃព្រាហ្មណ៍ ពេញព្រៀងផ្សាយហើយដោយបីតិ ។

៧– “និមិត្ត” ជាគ្រឿងចំណាំ-ជាហេតុ ឧ. ដើរ និង សម្គាប់ និមិត្តក្អក (ព្រោះក្អក-ព្រោះតែក្អក) ។

៨– “ជុំនុំ” ឬ “បណ្ដា” ជាសេចក្ដីដកញែកចេញឲ្យ ដាច់ដោយឡែកអំពីចំនួនដែលរួមដែលប្រមូលគ្នា ឧ. ជនុំឬបណ្ដា ភិក្ខុទាំងឡាយពីររូបនោះ ភិក្ខុមួយរូបផល់ហើយនូវសោតាបត្តិផល ៗ

៩– “ជិត” ឬ “ទៀប” ជាទីជិត-ប្រៀប ១. ស្រុកកាំងយជិតក្រុង ឬ ទៀបក្រុង, ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។

អាលបនៈ – អាលបនៈ ជាពាក្យសម្រាប់ប្រើជាសំដីស្រែកហៅ ឬពោលចំពោះ មានអាការៈដូចស្រែកហៅ ដូចពាក្យថា: “បពិត្រ, ម្នាល, នែ, ហៃ” តាមសេចក្ដីគោរព ឬពាក្យគោរព ១. បពិត្រមហារាជ សូមព្រះអង្គជំចំរើនទ្រង់ឈ្នះ, ម្នាល ឬ នែកូនប្រុកុំទៅ... ។

## ២៤— និបាតស័ព្ទ

និបាតជាស័ព្ទសំរាប់ផ្សំដើម្បីតែង់ឃ្លាល្បះមួយៗ ជាជំនួយនាមស័ព្ទនិងកិរិយាស័ព្ទ ឲ្យមានសេចក្ដីស្រឡះ ច្បាស់លាស់ពីរោះស្រួលស្ដាប់ ដូចពាក្យថា: ក៏ - ក៏ដោយ - ក៏ដែរ - ដែរ - ផង - ឯ - បើ - ទោះ - ទោះបី - បើទុកជា - ទើប - ពុំនោះសោត - ពាល - លុះត្រាតែ - ព្រោះ - ត្បិត ជាដើម ។ និបាតសំ

មានច្រើនយ៉ាងគឺ: អាយតនិបាតជាស័ព្ទសំរាប់ចងក្រងពាក្យ ដែលជាកម្មរបស់កិរិយា ឬជាពាក្យបំពេញបទរបស់នាមនាម ដូចពាក្យថា: ខ្ញុំស្តាប់នូវពាក្យ, វាទៅកាន់ផ្ទះ, កូនរបស់ខ្ញុំ, ភូមិផង, យើង . . . : ពាក្យ: នូវ, កាន់, របស់, នៃ... ជាអាយតនិបាត ។

អាយតនិបាតទាំងឡាយគឺ: រី, នូវ, កាន់, អស់, ញុំាង, ចំពោះ, ដោយ, គឺ, ហេតុ, ព្រោះ, ដល់, ចំរុង, អំពី, របស់, នៃ, កាលបើ, ទៀប, ជិត, និមិត្ត ។ (ដូចមានពិស្តារក្នុងខាងលើ)

## និបាតប្រាប់កាល - ប្រាប់ពេល (កាលត្ថជោតក:)

គ្រានោះ, លំដាប់នោះ, ដងនោះ, កាលនោះ, ក្សណនោះ, ព្រឹក, អំពីព្រឹក, ថ្ងៃ, ក្នុងវេលាថ្ងៃ, ល្ងាច, វេលាល្ងាច, ម្សិល, ម្សិលម៉ិញ, ពីម្សិលម៉ិញ, ស្អែក, ខានស្អែក, ខានស្អែកមួយ, អម្បាញ់មិញ, ភ្លាម, រំពេច, សិន, តទៅ, ក្នុងខាងមុខ ។ល។

## និបាតប្រាប់ទី (ឋានត្ថជោតក:)

ខាងលើ, ខាងក្រោម, ខាងក្រោយ, ខាងក្នុង, ខាងក្រៅ, ចន្លោះ, រវាង, ស្ងាត់, ទីស្ងាត់, កំបាំង, កំបាំងពីមុខ, ចំពោះមុខ, នៅមុខ,

ដទៃ, ឯមុខ, ឯនាយ, ឯអាយ, ភាគនាយ, អាយ ៗ ល ៗ

## និបាតប្រាប់សេចក្ដីប្រៀបប្រដូច (បរិច្ឆេទត្ថវាចកៈ)

ដូច, ដូចជា, ប៉ីដូច, ហាក់ដូច, ប្រដូច ប្រហែលដូច, យ៉ាំងណា, យ៉ាងណាមិញ, យ៉ាងនេះ, យ៉ាងនោះ, ដូច្នេះ, ដូច្នោះ, ដូចម្ដេចមិញ ៗ ល ៗ

## និបាតប្រាប់ប្រការ (បការត្ថវាចកៈ)

ម្ដេច, ដូចម្ដេច, ដោយប្រការដូចម្ដេច, ដោយប្រការនោះ ៗ ល ៗ

## និបាតប្រាប់សេចក្ដីឃាត់ហាមដាច់ខាត (បដិសេធនត្ថវាចកៈ)

កុំ, ពុំ, មិន, ឥត, ខាន, ពិត, មែន, តែប៉ុណ្ណោះ, គ្រាន់តែ, មិនមែន, មែនពិត, វៀរលែង, វៀរលែងតែ, លើកលែងតែ, កុំឡើយ, ណ្ហើយ, ល្មមហើយ ៗ ល ៗ

## និបាតប្រាប់សេចក្ដីតាមបានឮ (អនុស្សវនត្ថវាចកៈ)

ឮថា, បានឮថា, មានដំណាលថា ៗ ល ៗ

## និបាតប្រាប់សេចក្ដីជញ្ជឹង-ប្រមើល-ស្មាន-ណាត់

(បរិកប្បត្ថវាចកៈ)

បើ, បើថា, ប្រសិនបើ, ទោះបី, ល្គឹកកែ, បើដូច្នោះ, ធ្វើដូច, ម្ដេចហ្ន៎ ។ល។

## និបាតប្រាប់សេចក្ដីសួរដំណឹង (បុច្ឆនត្ថវាចកៈ)

ឬ, ឬក៏, ឬអី, ឬទេ, ដូចម្ដេច, ដែរឬ, យ៉ាងដូចម្ដេច, យ៉ាងណា, ទដឹង, យ៉ាងណានេះ, អេះ, ហ៎, ហ្ន៎, ។ល។

## និបាតប្រាប់សេចក្ដីឆ្លើយ-ទទួល (សម្បដិច្ឆនត្ថវាចកៈ)

អើ, បាទ, ព្រះបាទ, ព្រះបាទម្ចាស់, ករុណា, ករុណាពិសេស, ចា៎ះ, ច៎ះ, ពរម្ចាស់, មែ, ព្រះមែម្ចាស់, បំរើនពរ, ថ្វាយព្រះពរ ។ល។

## និបាតប្រាប់សេចក្ដីតឿន (បយោជនត្ថវាចកៈ)

ហ៎, ដូចជាគៀន, ឆាប់ៗ ។ល។

## និបាតប្រាប់សេចក្ដីច្រើនយ៉ាង (អនេកត្ថវាចកៈ)

ក៏, ឯ, ដ្បិត, ក្ដី, ផង, មួយ, ខ្លះ, ឬ, ពិត, មែន, ផ្ទុរ, អើក៏, មែនពិត, ពីព្រោះ, ក៏ដោយ, ក៏បាន, ពុំនោះ-

សោតមួយវិញទៀត, ចំណែកខាង. ប៉ុន្តែ, ប៉ុន្តែថា, ថ្វីបើ, ក្រែង, ដូចជា, ម្យ៉ាងទៀត ។ល។

## និបាតប្រាប់សេចក្ដីគ្រាន់តែបំពេញបទ (បទបូរណត្ថជោតកៈ)

ណា, ហ៎, ហះ, យី, យើ, ឯង, ទ, យីអើ ។ល។

## និបាតប្រាប់សេចក្ដីផ្សេងៗ (នានត្ថជោតកៈ)

មែន, ខុស, ទទេ, ទៀត, វិញ, ខ្ពស់, ទាប, ប្រាកដ, ដោយពិត, ទៅវិញទៀត, ក្រៃពេក, ក្រៃលែង, រឿយៗ, ញឹកញយ, ជាក់លាក់. ពីចម្ងាយ, ក៏មែនហើយ, សូម្បី, តិចតួច, ចាប់ដើម, តាំងពី, ពីដូច, ពុហាក, មួយគ្រា, ម្ដង, តិចៗ, សន្សឹម, សំរៀម, ថ្មៗ, ញឹបៗ, មួយរយដង, មួយសទ្ទើ, ជាមួយ, ខ្លួនឯង ។ល។

## និបាតប្រាប់សេចក្ដី (ជាគាលបទៈ)

សំរាប់អ្នកគ្មានតេជះ ទៅកាន់អ្នកមានតេជះ ឬអ្នកមានតេជះ ទៅកាន់អ្នកគ្មានតេជះ ។

(កាលបន្តក្រោយ:) សូមព្រះតេជះ, សូមព្រះតេជះ ជំគល់លើត្បូង, សូមទ្រង់មេត្តាប្រោស, សូមទានមេត្តាប្រោស, ទានប្រោស, បពិត្រព្រះអង្គ, បពិត្រព្រះករុណា, បពិត្រលោកដ៏ចំរើន, នែនាយ, នែពៅ, ព្រះស្ដែង, រុំ, រុយ, នែអ្នកដ៏មានអាយុ, នែអ្នកដ៏ចំរើន, អស់លោកទាំងឡាយ ។ នាង អានាង... ។ល។

## ឧទានសព្ទ

សព្ទសម្រាប់ប្រាប់សួរសំឡេង ឬជាសម្លេងភ្ញាក់ទាត់ដោយភ្ញាក់ផ្អើល ព្រោះមានភ័យ ឬមានសេចក្ដីត្រេកអរត្រេកពេក ។ ម៉ែក! ប៉ុន! ត្រាន! ប៊ែមៗ! កឹង! វ៉ែកៗ! ហ៊ុន! ខ្ញុំខ្ញូន! ពុទ្ធោ! កម្ម! ។ល។

## បរិវារសព្ទ

មានពាក្យខ្លះឥតសព្ទប្រែ សំរាប់តែបន្ថែមសំដី ពាក្យទាំងនោះហៅថាបរិវារសព្ទ ។ ជាធម្មតា បរិវារសព្ទភ្ជាប់នឹងនាម ឬនឹងគុណនាម មានលំនាំដូចអតិវិសេសគុណនាម ។ ពាក្យទាំងនោះគឺ: ប្រអប់ប្រអូង, ចានក្បាន, ផ្ទះសម្បែង, ស្លស្លុក,

ចំណីចំណុក, ព្រៃផ្សៃ, គោអំពៅ, សេះអំពែះ, មនុស្សម្នា, ចិនព្រិន, យួនព្រួន, ម៉េះម៉ា, ក្មេងក្មាង, ថ្នាំសង្កូវ, ស្មៅព្រៅ, ដំណាំដំណោប, សត្វពន្លាត់, ឧំនែក, ខុស្រាប់អាសាញ់, ស្ទុះស្ទាយ, ស្ទោកស្ទាំង, ក្មេងក្មាត់, ដំបងព្រនង់ ។

## ២៥–សំខ្យា ឬ សំខ្យាស័ព្ទ

សព្ទសំកប់កប់នាមហៅថាសំខ្យាស័ព្ទ ។ សំខ្យាស័ព្ទមាន ពីរយ៉ាងគឺ បកតិសំខ្យា និងបូរណសំខ្យា ។

### បកតិសំខ្យា

សំខ្យា ដែលកប់តាមប្រក្រតីឲ្យដឹងចំនួនរបស់នាមនាមថា ប៉ុណ្ណេះ ប៉ុណ្ណោះ ដូចកប់ថា: មួយ - ពីរ - បី - បួន - ប្រាំជាដើម ហៅថាបកតិសំខ្យា ។

### បូរណសំខ្យា

សំខ្យាដែលកប់នាមនាមបង្គ្រប់ជាជាន់ៗ តាមលំដាប់តាមថ្នាក់ ដូចពាក្យថា ដំបូង :(ទីមួយ)· គំរប់ពីរ · គំរប់បី · គំរប់បួន · គំរប់ប្រាំ

ជាដើមនឹងពាក្យថា: បឋម: - ទុតិយ: - ចតុត្ថ: - បញ្ចម: - ឆដ្ឋ: ហៅថាបូរណសំខ្យា ។

បកតិសំខ្យាមានពីរពួកគឺ: សំខ្យាសព្ទនាម១, សំខ្យាគុណនាម ១ ។ សំខ្យាសព្ទនាមមានដូនគឺ: មួយ - ពីរ - បី - បួន ។

សំខ្យាសព្ទតាំងពីប្រាំកទៅសឹងជាគុណនាមទាំងអស់ ។ ឯបូរណសំខ្យាជាគុណនាមទាំងអស់ដែរ ។

វិធីប្រើសំខ្យសព្ទ – នឹងរាប់វត្ថុ ៗ គេដាក់សំខ្យានៀងភ្ជាប់ពីក្រោយនាមនាម ឬភ្ជាប់ខាងមុខនាមនាម តាមដោយចំនងស្រួលជាក្នុងភាសា ។ ដូចរាប់ថា ១ រៀល - ពីររៀល - មួយពាន់ម៉ែត្រ - មួយសែនហាប - មួយលាននាក់ : .. គោពីរ - សេះហុកសិប - ឥដ្ឋមួយម៉ឺន - ពាហនមួយកោដិ - ស្វាយប្រាំស្ទឹក ... កូនជម្រង - ថ្នាក់បន្ទាប់ - សេចក្តីគំរប់ប្រាំពីរ - បឋមដ្ឋាន - បឋមាសាធ - ទុតិយវិជ្ជា - បញ្ចម៍ទោសថ ។ ល ។

## ២៦ -- បុព្វបទ

អ (សំរាប់បដិសេធ) ស័ព្ទ «អ» ជាស័ព្ទសំរាប់បដិសេធ ។

“អ” បដិសេធនេះសំរាប់រៀងភ្ជាប់នឹងស័ព្ទដទៃ សេចក្ដីខាងន័យ

ជា: ពុំ - មិន - ឥត - មិនមែន ដូចពាក្យ: អកតញ្ញូ - អភ័ព្វ - អកុសល -

អភ័យ - អទុក្ខ - អរោគ - អចត្តា - អកម្ម - អគតិ - អគោចរ... ជាដើម ។

«អ» បដិសេធនេះប្រែជាបុព្វបទហៅថា “អ»បុព្វបទ ។ មានបុព្វបទ

ឥតមួយទៀត សំរាប់រៀងភ្ជាប់ខាងដើមពាក្យ ។ បុព្វបទទាំងនោះ

មានន័យថា ឲ្យ...: ធ្វើឲ្យ... ដូចពាក្យថា: កកាយ - បញ្ចូល -

បណ្ដាញ - បង្អិល - បន្ទូរ - បង្ហួយ - បង្ខូម - បណ្ដើរ - ទទាស់ទទែង -

បង្រួប - បំបាត់ - បញ្ចប់ - បង្រៀន... ជាដើម សុទ្ធជាពាក្យ

ផ្សំអោយបុព្វបទ ក ប ញ បណ បន ញ ទ បំបង... ។

## ២៧ -- អាគម

គេហៅថាអាគមគឺអក្សរបុះថែមត្រង់ចន្លោះដូចពាក្យថាៈ ចតុរង្គ-និរន្តរ-បរិយោសាន-ចតុរារិយសច្ច... ។ ចតុ-អង្គ ជាចតុរ-អង្គ ជាចតុរង្គ, និ-អន្តរ ជានិរ-អន្តរ ជានិរន្តរ, បរិ-ឱសាន ជាបរិយោ-ឱសាន ជាបរិយោសាន, ចតុ-អរិយសច្ច ជាចតុរ-អរិយសច្ច ជាចតុរារិយសច្ច, អក្សរ រ-យ ដែលយកមកថែមដើម្បីសំរួលស័ព្ទអាន ហៅថា អាគម ។ អាគម សំរាប់ប្រើតែក្នុងភាសាបាលី និងភាសាសំស្ក្រត នោះអក្សរដែលយកមកប្រើជាអាគមមានចំនួនសំរេច ។

## ២៨-- ឧបសគ្គៈ

ឧបសគ្គ ជានិបាត និងជាអព្យយស័ព្ទ ( ពាក្យមិនផ្លាស់ប្តូររូបនិងស័ព្ទ ) ដូចជានិបាតនានាដែរ តែពួកនិបាតដែលហៅថា

ឧបសគ្គៈនោះ មានចំនួនតែ ២០ ស័ព្ទៈហើយមានរបៀបបែបផែនក្នុងវិធីបង្កើតពាក្យដោយឡែកផ្សេងពីនិបាតនានា ។ ក្នុងការបង្កើតភ្ជាប់ពាក្យ គេដាក់ឧបសគ្គៈជាខាងដើមនាមស័ព្ទ រឺកិរិយាស័ព្ទ ។

ឧបសគ្គៈទាំង ២០ ស័ព្ទគឺៈ

អតិ ប្រែថា កន្លង - ក្រៃ - ក្រៃពេក - ពេក . . .

អធិ — ក្រៃលែង - ក្រៃពេក - លើសលុប - លើសលែង - សន្ធឹក

អនុ — តាម - តូច - បន្ទាប់ - រង - ក្រោយ - បណ្ដោយ - លំដាប់

អប — ប្រាស - គេច - វៀស . : .

អបិឬបិ — ជិត - ខាងលើ . . .

អភិ — ក្រៃពេក - ធំ - ចំពោះ - ឆ្ពោះ - ខាងមុខ . :

អវឬឱ — ចុះ - ចុះក្រោម - ទាប - ស្រោប . . .

អា — ទូទៅ - សព្វ - ក្រៃលែង . . .

ឧ — ឡើង - ខ្ពស់ - ក្រៅ . . .

ឧប — ជិត - ចូលទៅជិត - មាំ - ស៊ប់ . . .

ទុ — អាក្រក់ - ក្រ - កម្រ - លំបាក . . .

ប្រែថា ចេញ-មិនសល់-មិនមាន-ឥត...

និ — ចេញ-ចូល-ចុះ...

ប — ទូទៅ-ខាងមុខ-ចេញ មុខ...

បដិ-បតិ — ចំពោះ-តប-ត-ប្រាស-ត្រឡប់...

បក — ខាងមុខ...

បរិ — ជុំ-ជុំវិញ-គ្រប់គ្រាន់-ស្រេច..

វិ — ផ្សេង-ប្លែក-ច្បាស់-ជាក់-ប្រាកដ...

សំ — ព្រម-ជាមួយ-ល្អ-ប្រពៃ...

សុ — ងាយ-ស្រួល-ស្រណុក-ល្អ-ប្រពៃ-ណាស់-ម៉េះ...

ពាក្យដូចមានតទៅសឹងជាពាក្យមានឧបសគ្គៈ

បរិបូណ៌ ទុរគត(ទុគ្គត)បរាជ័យ-អនុគ្រោះ-អភិបាល-អធិការ-អវសាន-(បរិ-នុសាន)បរិយោសាន-ឧបរាជ-និរភ័យ-អធិបតី-វិកាល-វិបរិត-សុវិជ្ជា-ទុវិជ្ជា-អបរាជ័យ-និរន្តរ-និរទោស-អធិជ័យ-អនុនាយក-អនុស្សាវនា-សុគតិ-សុគន្ធ-វិជ័យ-ទុក្ខ...។

## ២៩— សម្ពន្ធ

សម្ពន្ធជាគ្រឿងតនឹងបទ ឬបទប្រយោគ ៗ ដើម្បីភ្ជាប់ពាក្យបទជាបទក្នុងសង្កាត់មួយៗ ឬក្នុងប្រយោគមួយ ត្រូវឲ្យដឹងថាបទណានូវប្តូរទៅរកបទណា តាមលំនាំវេយ្យាករណ៍ ។

ឧទាហរណ៍ៈ ១ — “ឈ្មួញ ដឹក ស្រូវ”

ឈ្មួញ : នាម, សាធារណៈ, ឯកវចនៈ, បឋមបុរសៈជាប្រធានរបស់កិរិយា ដឹក ។

ដឹក : សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ។

ស្រូវ : នាម, សាធារណៈ កម្មនៃកំពើ ដឹក ។

២ — “ស្ត្រីៗ ទូល បន្លែ ដោយ កញ្ជើ”



ស្ត្រីៗ, នាម, សាធា. ពហុ. បឋមបុរសៈ ជាប្រធានរបស់ កិរិយា ទូល ។

ខូច : សកម្មកិរិយា, បច្ចុប្បន្នកាល, ពហុ ។

បន្ទុះ : នាម, សាធា. ពហុ. កម្មវត្ថុនៃកិរិយា ខូច ។

ដោយ : គាយកនិបាត

កញ្ចោ : នាម, សាធា. ឯក. អកម្មវត្ថុនៃ ខូច ។

" បងខ្ញុំ សង់ ផ្ទះថ្មីមួយ នៅផ្លូវនរោត្តម "

បងខ្ញុំ : បទមាត្រសព្ទ (កាត់បទពីបងរបស់ខ្ញុំ ឬបងនៃខ្ញុំ),

នាម, សាធា. ឯក. បឋមបុរិស: ជាប្រធានកិរិយា សង់ ។

សង់ : សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ។

ផ្ទះ : នាម, សាធា. ឯក: កម្មវត្ថុនៃ សង់ ។

ថ្មី : បកតិគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

មួយ : សំខ្យាគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

នៅ : និបាតប្រាប់វិ ។

ផ្លូវនរោត្តម នាម: អសាធា. ឯក. អកម្មវត្ថុនៃ សង់ ។

## ៤ — "ឯង កុំដើរលេង ឡើយ"

ឯង: មធ្យមបុរស: (ម. បុ. សព្វ) ប្រធាន ដើរ

លេង: ឯក. ។

ដើរលេង: សកម្មកិរិយា, ឯក. បច្ចុប្បន្នកាល ។

កុំឡើយ: និបាត បដិសេធ (បដិសេធនត្ថាបក:)

## វិធីហាត់

១ — ចូរដាក់លិង្គទៅខាងមុខនាមនិមួយៗ ៗ ឧបមាដូច ប្រុស (បុំលិង្គ) ស្រី (ឥត្ថីលិង្គ)

| | | |
|---|---|---|
| ប្រុស... | យក្ខ, យក្ស... | ហត្ថី .. |
| ស្រី..., | យក្សា... | ហត្ថិនី ... |
| ឪពុក... | យក្ខិនី... | ទ្វី... |
| ម្ដាយ... | យក្សិណី... | ម៉ាក់... |
| មា... | ទេវបុត្ត... | ពាជី ... |
| មីង... | ទេវធីតា..., | ពាជិនី ... |

| | | |
|---|---|---|
| តា... | នាងមេខលា... | តារី... |
| យាយ... | កិន្នរ... | ពានរ... |
| កុមារ... | កិន្នរា... | ពានរី... |
| កុមារា... | កិន្នរី... | ទាយក... |
| កុមារី... | បក្ខ, បក្សា... | ទាយិកា... |
| ភិក្ខុ... | បក្សី... | ឧបាសក... |
| ភិក្ខុនី... | ព្រាហ្មណ៍... | ឧបាសិកា... |
| សាមណេរ... | ព្រាហ្មណី... | សិក្ខមានា... |
| សាមណេរា... | ចោរ... | ទាសី... |
| សាមណេរី... | ចោរី... | ទាសា... |

២– ចូរដាក់វចនៈ ត្រង់ពាក្យនាមនាមនិមួយៗ ឲ្យមានដូចមនុស្សទាំងឡាយ (ពហុវចនៈ ឬពហុ.) របស់, ( ឯកវចនៈ ឬឯក.)

| | |
|---|---|
| មនុស្សទាំងឡាយ... | សិស្សានុសិស្ស... |
| ឈើ... | ក្រស្តប្រដា... |

# ៦២ - ហ្វឹក មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

| | |
|---|---|
| ក្មេង . . . | ជនានុជន . . . |
| ផ្លែទាំងឡាយ . . . | ឋានានុក្រម . . |
| ពជាទាំងឡាយ . . . | របស់ទាំងឡាយ . . . |
| សេះប្រាំ . . . | ពស្ត្រា . . . |
| ដំរី . . . | ផ្ទះទាំងឡាយ . . . |
| រទេះទាំងឡាយ . . . | ព្រាហ្មណ៍ . . . |
| ឬស្សី . . . | ភោជនាហារ . . . |
| កុមារ . . . | ទោសានុទោស . . . |

៣ - បកតិគុណនាម

| | | | |
|---|---|---|---|
| ល្អ | ប្រសប់ | ខ្ពស់ | ភរ |
| មាំ | ស្រួយ | ទាប | ឆាប់ |
| ជាប់ | ធុយ | ស្ងើត | ក្រអូប |
| ស្គម | រឹង | កំរក់ | ស្អុយ |
| ពូកែ | ទន់ | ភ្លឺ | ស្រួប |

| | | | |
|---|---|---|---|
| ធាត់ | ធំ | ស្រគាប់ | តាល |
| ស | តូច | ខ្លី | ត្រង់ |
| ខ្មៅ | ស្តើង | វែង | វៀច |

៤- ចូរភ្ជាប់គុណនាមដូចមានខាងលើ នឹងនាមនាមមួយៗ តាមសមគួរ ៗ ឧបមាដូចៈ ខ្សែវែង - ក្មេងគំរក់ - ចុងកាំបិត... ។

| | | |
|---|---|---|
| ខ្សែ... | ភ្នំ... | បន្ទាត់ ... |
| ក្មេង... | បេស... | ផ្លូវ.. |
| របង... | ស្លឹក... | មួក... |
| ឈើ... | មេឃ... | ជ្រក... |
| ផ្លែ... | កន្លែង... | ទឹក... |
| មេទាហាន... | កង... | ក្ដារ... |
| ក្រដាស... | មនុស្ស... | ដែក... |
| ផ្សែង... | ភ្លើង... | ដានខង... |
| ដាន... | តញ្ញាក់... | កែវ... |

## ៦៤– ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

| | | |
|---|---|---|
| ដស ... | ចង្កូលដៃ ... | ព្រះអាទិត្យ ... |
| ឥដ្ឋ ... | វត្ត ... | ចាន ... |
| ថ្ម ... | ផ្កា ... | ក្រមួន ... |
| ត្បូក ... | កន្ទេល ... | ដំបៅ ... |

### ៥– អតិវិសេសគុណនាម

ខ្មៅណាស់ លឿនក្រូត ស្រួយខ្វាក តឹងម៉ឹង

ម៉ដ្ឋស្មុង ខ្ពស់ត្រដែត ធំធេង វែងសន្ធន់

ក្តៅឆោង ខ្ទីក្រឡុញ សក្បុស ពាបធេង

ថ្លាយង់ ឆើតឆាយ ខៀវស្រអាក់ ស្ដើងហៀវ

រហ័សប្រិល ឆ្ងាយសន្ទឹម ធុយរគម មូលក្រឡង់

៦– ឲ្យនាមនាមទាំងនេះ ប្រើជាក់លក្ខណៈតាមគួរសម នឹងអតិវិសេសគុណនាមទាំងលើនោះឯង ។ ឧទាហរណ៍ ៖ សក់ ខ្មៅរលើង...ៗ

សក់មានពណ៌ ... កល់ផ្កាយពណ៌ផាកល ...

| | |
|---|---|
| ក្មេងនេះមានសាច់... | បានជាវត្ត ... |
| ខ្ញុំមានតុ ... | មើលទៅឃើញភូមិ... |
| ទឹកនេះ... | ភ្នំនោះមានពណ៌ ... |
| មនុស្សនេះ ... | ឈ្មោះជាសរសៃ ... |
| ព្រាយហោះ... | គេបង់ចំណង ... |
| ថ្ងៃឡើង ... | កែបនេះប្រកគារ ... |
| ម្រាមដៃក្មេង ... | ភូមិនេះសង់លើដី ... |
| កងរបស់កុមារនេះ ... | ជញ្ជាំងផ្ទះនេះធ្វើពីក្តារ ... |
| ព្រៃនោះ ... | ព្រះអាទិត្យមានរង់ ... |

## ៧ – វិសេសគុណនាម

| | | | |
|---|---|---|---|
| បេះជាង | ប្រសប់ជាង | ជាប់ជាង | ខ្មៅលើស |
| យឺតជាង | រហ័សជាង | ផុយជាង | សប្លែក |
| ល្អប្លែក | ខ្ពស់លើស | រឹងជាង | ល្អិតជាង |
| ថ្លាជាង | ឆាត់ប្លែក | ទន់ជាង | ទាបជាង |

៨– ចូរដាក់លក្ខណៈនាមបមត្ថរ ទីនពាក្យនីមួយៗ ដោយវិសេសគុណនាមខាងលើ ។ ឧទាហរណ៍: ក្មេងនេះប្រសប់ជាង, កូនបិស្សនោះឆ្លាតជាង ... ។

ក្មេងទាំងឡាយ ក្មេងនេះ... ។ ឈើជាប់នោះផ្លឹកជាឈើ... ។ យានទាំងឡាយ រទេះគោ ... ។ ត្បូងពេជ្ររត្ន... ត្បូងទាំងអស់ ។ ភ្នំនៅស្រុកខ្មែរ-ភ្នំបូកគោ ... ។ គ្មានរបស់អ្វី... ជាងថ្ម ។ ទឹកម៉ាស៊ីន... ទឹកស្រះ ។ ដែលជាលោហធាតុ... ធាតុឯទៀត ។ ស្បែកមនុស្សទាំងពួង ស្បែកបារាំង... ។ គ្មានអ្វី ... លើសម្រ័ក្សណ៍ខ្មែរ ។ ធម្មជាតិល្អិត គ្មានអ្វី ... អាកាស ។ វត្ថុទន់នោះសំឡីជាសរសៃ ... ។

៩– នូវកិរិយាទាំងឡាយ ចូរបំបែកជាកិតនាម ឬ នាមក្រិត ។ ឧបមាដូចពាក្យៈគិត ជាគំនិត, ខ្ទប់ ជាបន្ទប់... ។

គិត... កាត់... សិត... គូស...

ចង... កោស... សូន... កាន់...

ឈាន... ដឹង... ដួញ... បិត...

ដោរ ... ទើរ ... ចិញ ... គេណ ...

ដើរ ... ខ្ញុញ ... បក ... សៀក ...

ដេក ... បួស ... ប៉ះ ... កោរ ...

ដាំ ... ប្ដូរ ... កាត់ ... គាល់ ...

ទំ ... ពូន ... រៀប ... សួរ ...

១០ – ចូរកែនាមកើតចេញពីគុណនាមមួយ ៗ នេះ ។

ឧបមាដូច : ធ្ងន់ ជាទម្ងន់ ... ។

ធ្ងន់ ... ខ្ពាក់ ... ចាំ ... ធំ ...

ទាប ... ខ្ពិន ... ស្អុយ ... ក្រាស់ ...

ខ្ពប់ ... ឈឺ ... ឆ្ងាប ... ខ្ពិល ...

ស្រាល ... បេះ ... ផ្អែម ... ឆ្ងាញ់ ...

រឹង ... ថ្លៃ ... ក្ដៅ ... ល្អក់ ...

ល្អិត ... ស្ដើង ... ចាស់ ... ចាស់ ...

លោក ... គាប ... ល្អ ... កួច ...

# ៦៨–ថ្នាក់មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

១១– ចូររកកិរិយាកើតចេញពីពាក្យមួយៗខាងក្រោមនេះ ។

ដូចពាក្យ: ត្រង់ ជា ដំរង់ ឬ តម្រង់ . . . ។

ត្រង់ . . . ដំរៀល . . . ចំនាយ . . . ទ្រនាប់ . . .

ត្រួវ . . . បំណាញ... បំណាស់... ចំណាប់...

ដំណោះ... បំណោទ... បំណុល... ស្អាត...

ជ្ជើរ... បំណាយ... អំនួត... ផ្គត់...

ចំនើប... ព្រើន... ទ្រទំ... ក្តៃន...

១២– ចូរភ្ជាប់បុព្វបទ " ក-ប-ប្រ-បង់-ប ញ-បណ-បន-បំ-ទ-ញ" នឹងពាក្យកិរិយានិមួយៗ តាមដោយសមគួរ ។

ដូច: កាយ ជា កកាយ, ការ ជា បង្ការ ។

កាយ . . . ជូន . . . រួម . . . ដុល . . .

ការ . . . ដោរ . . . ថែម... មើល . . .

ខាក . . . ឈ្មោះ . . . ករ . . . ខាំ . . :

គរ . . . ឈឺ . . . ខាន . . . ទំ...

គាប់... ដេញ... ណាត់... ពាញ...

ចូល... ដើរ... ភ្លេច... រួញ...

ចេញ... ធំ... ថែរ... ចាប់...

ធុក... រៀន... បិទ... ញឹម...

១៣ — ចូររកបុព្វបទដែលមានន័យថា: "ធ្វើឲ្យ" មកភ្ជាប់នឹងពាក្យនិមួយ ៗ នេះឧបមាដូចពាក្យ: "ធំ ជា បង្ធំ" ។

ធំ... រត់... រៀប... ខាំ...

កាប់... ផល់... វែក... ខូច...

ស្លាប់... ដឹង...... ហាត់... រួម...

កើត... ខាន... រលំ... រឹត...

រៀន... ឡើង... យល់... ផ្សំ...

ឈឺ... ចុះ... ចាប់... ដុះ...

ដេក... ភ្លឺ... សិក្ខ... ផ្អាប់...

ឈរ... ទុំ... ចាល់... ប្អឹង...

១៤ — ចូររកគុណនាមដោយគួរតាមគាត មកបំពេញបទនៃពាក្យទាំងនេះ ៗ ឧបមាដូចពាក្យថា: "ពស់មានពិសជាលក្ខណៈ" ។

# ៣០ – ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន



ពស់មានពិសជាសត្វ . . . ។ មនុស្ស . . . គឺមនុស្សដែលមានរូបអវយវៈ ។ ខ្លាជាម្រឹគ . . . ។ គគីរជាឈើ . . . ហើយ . . . ណាស់ ។ ក្ងោកខ្លាលជាបក្សី . . . . ។ ថ្មជាធាតុមួយ . . . . ។ មនុស្សឈឺមានកាយ . . . ។ ផ្លែឈើទុំញាសមានក្លិន . . . ។ អ្នកទុគ៌តជាមនុស្ស . . . ។ ព្រះចន្ទពេញបូណ៌មីមានរង្វង់ . . . ។ ទឹកសមុទ្រមានរសជាតិ . . . ។ ក្រឹងជាធាតុ . . . ។ ដែកជាលោហធាតុ . . . ។ មេឃ . . . គឺមេឃដែលគ្មានពពក ។ លោហធាតុ . . . គឺសំណ . . . ។ ខ្យល់ពីងដើរជាខ្យល់ . . . ។ ពេជ្រជាត្បូង . . . ហើយ . . . បំផុត ។ ស្លាជារុក្ខជាតិមួយ . . . បំផុត ។ មនុស្សធ្វើការបានហើយជាមនុស្ស ។ ព្រះអាទិត្យមានរស្មី . . . ។

១៥ – ចូររកកិរិយា មកភ្ជាប់នឹងប្រធាន :

ឧទាហរណ៍: ព្រះអាទិត្យ បំភ្លឺ លោក . . . ។

ព្រះអាទិត្យ . . . លោក ។ ជាងដែក . . . លោហធាតុនឹងស្ងប់ ។ ព្រះចន្ទ្រ . . . យប់ ។ ជាងបាយអ . . . ឥដ្ឋធ្វើកំពែងវាំង ។ ព្រះធរណី . . . មនុស្សនូវសត្វ, ត្រីខ្សាន នៅក្នុងសំណុំព្រះកម ។ គ្រូ . . . សិស្ស ។ ពស់ . . . វ៉ឹករ៉ក់ ។ ច្បាប់ . . . ឲ្យយើងប្រតិបត្តិតាម ។ អណ្ដើក . . . ក្នុងទឹកនឹងលើគោក ។



យើង . . . ប្រណិប័តន៍អាពុកម្ដាយ ។ អ្នកនេសាទ-ត្រី . . . សំណាញ់ ។ ជាងចង . . . មាសធ្វើប្រអប់ ។ ព្រានព្រៃ . . . សត្វនឹងស្នា ។

# ៧២ - ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

 

១៦ - ចូររកប្រយោគតាមសភាពភ្ជាប់នឹងកិរិយានីមួយៗនេះ ។

ឧទាហរណ៍ : ចោរ លួច ទ្រព្យគេ ... ។

... លួចទ្រព្យគេ ។ ... កៀរត្រីនឹងព្រួល ។

... រៀនអក្សររៀនលេខ ។ ... បរដំរីនឹងកង្វេរ ។

... លេបកង្កែប ។ ... ជាផលជាតិ ។ ... សិក្សាធម៌ ។

... រស់នៅក្នុងទឹក ។ ... ដេញទន្សាយ ។ ... ចំឡងពាក្យដែលគ្រូបង្គាប់ ។ ... លប់សំពត់ក្នុងសាលាទាន ។

... ពន្យល់ពាក្យនៅការរៀន ។ ... ធ្វើទានចំពោះសង្ឃ ។

... ដំដែកនឹងញញួរ ។ ... តយុទ្ធនឹងសត្រូវ ។ ... អុំទូកនឹងច្រវ៉ា ។

១៧– ចូររកពាក្យផ្ទុយនឹងពាក្យទាំងនេះ :

ឧទាហរណ៍: មនុស្សផ្គត់ផ្គង់: មនុស្សខ្ជះខ្ជាយ ...។

មនុស្សផ្គត់ផ្គង់...។ ផ្លូវត្រង់ហើយវែង...។ ក្មេងខ្សោយ...។ សេះធាត់...។ កូនសិស្សខ្ជាប់ខ្ជួន...។ ឈើស្ងួត...។ ជាងប្រសប់...។ ដៃគរង... សំណា...។ មនុស្សអ្នកមាន...។ គាប់ស្អុយ...។ ផ្កាបម្យ...។ មនុស្សពាល...។ មាសលៀនទុំ... ព្រាក់...។ ឆ្កែកាច...។ យប់ងងឹត... ថ្ងៃ...។ ផ្លែឈើទុំ...។ ក្របីទាញក្តៅ... គោទាញ...។ ស្បែករគ្រាត...។ សេះលឿន... គោ...។ កាំបិតមុត...។ ខ្វាំហើយសាហាវ... ឆ្មា... ហើយ...។

១៨ – ចូររកពាក្យមកបំពេញកន្លែងចន្លោះ

ជនណាប្រតិបត្តិតាមច្បាប់នឹងបានសុខ, ជនណា... ច្បាប់នឹងមានទោស ។ ក្នុងសម័យដែលស្រុកសុខ, ការទាំងពួងបានចំរើន ។ ក្នុងសម័យដែលស្រុកមាន..., ការទាំងពួងនឹងអន្តរាយ ។

មនុស្សណាដែលគិតតែសុខ, អ្នកនោះនឹងបាន... ។ នរណាយកទុក្ខមកជាទីតាំង, អ្នកនោះនឹងបាន... ។ ជនណាឃើញខ្លួនឯងជាមនុស្សក្រ, ជននោះនឹងជាអ្នក... ។ ជនណាឃើញខ្លួនឯងជាអ្នកប្រាជ្ញ, ជននោះជាបុគ្គល ... ។ នរណាតាំងខ្លួនជាខ្ពៅ, នរណានោះជាអ្នក ... ។

១៩ – ចូររើសរកពាក្យដែលមានន័យប្រហែលគ្នា (វេវចនៈ) នឹងពាក្យដូចមានតទៅ ៖

ឧបមាដូច: ចរ គឺ ត្រាច់ - ទៅ - យាង - និមន្ត ...

| | | | |
|---|---|---|---|
| ចរ... | យំ... | សំដៅ ... | បញ្ជូន ... |
| ដេក ... | ទិញ... | បិទ ... | ប្ដឹង... |
| ស៊ី... | ឲ្យ... | ដក... | ប្រដៅ... |
| មើល... | លេង... | លុប... | កាត់... |
| គិត... | ឈឺ... | បំពេញ... | បំភ្លឺ... |

# ៣០ - សមាសនាម

នាមនាមមានច្រើនយ៉ាង ៗ នាមដែលកើតឡើងឯង ៗ ហៅជាបកតិនាមដូចពាក្យៈ ផ្ទះ - សេះ - ដី... ។ នាមដែលបែកចេញពីកិរិយាឬពីគុណនាមហៅជានាមក្រិត ឬកិតនាម ដូចពាក្យៈ ដំណើរ-ជំនូន ( មកពីដើរ - ពីជូន ) ។

នាមដែលភ្ជាប់គួបគ្នាពីរពាក្យ ឬច្រើនពាក្យជានាមមួយហៅជាសមាសនាម ។ សមាសនាមជានាមគួបគ្នាដោយ នាមនឹងនាមក៏មាន, ដោយនាមនឹងគុណនាមក៏មាន ដោយនាមនឹងកិរិយាក៏មាន, ដោយកិរិយានឹងកិរិយាក៏មាន; សមាសនាមមានពីរយ៉ាងគឺ: នាម-សមាសបាលី ១, នាមសមាសខ្មែរ ១ ។ នូវនាមសមាសបាលី បើកាលណាពាក្យដែលមកមកភ្ជាប់ ជាពាក្យកើតឡើងអំពីស្រះពេញត្រូវផ្លាស់ស្រះនោះជាស្រះទិស្រ្យ័យ ឧបមាដូចពាក្យៈ "គជ-ឥន្ទ្រ ជាគជេន្ទ្រ" "ជន - អធិបតី ជាជនាធិបតី" ។ សមាស-នាមពាំងឡាយគឺ: ជន្លូវទាង - ពស់វែក - ក្រដាសប៉ុយ • ដើងម៉ា •

# ៣៦ — ថ្នាក់ មជ្ឈិមដ្ឋាន នឹង ឧត្តមដ្ឋាន

ត្រប់ស្រួយ · គោសៀម · ថ្នាំគុឡា · ផណ្តើរ · ជនានុជន · សក្កពិការ · លោកុត្តរ · សាសនោបាយ · ទេវិទ្ធ ... ។

## វិធីហាត់

ចូរសរសេរកម្រែសមាសនាមដូចមានខាងក្រោម :

សិស្ស + អនុសិស្ស = សិស្សានុសិស្ស ។ លោក + ឧត្តរ = ... ។ ជន + អនុជន = ... ។ លោក + ឥស្សរៈ = ... ។ គុណ + អានិសង្ស = ... ។ ពានរ + ឥន្ទ្រ = ... ។ ផល + អាហារ = ... ។ សាសនៈ + ឧបាយ = ... ។ សត្វ + អធិដ្ឋាន = ... ។ ពុទ្ធ + អនុញ្ញាត = ... ។ គុណ + ឧត្តម = ... ។ ជន + អធិបតី = ... ។ ឧបជ្ឈាយ៍ + អាចារ្យ = ... ។ នរ + ឧត្តម = ... ។ ជន + អនុគ្រោះ = ... ។ គាថា ... ផ្ទះវៀរ ... ដើមចាំ ... ណាវ៉ែ ... រទេះគោ ... ។

ក្នុងភាសាខ្មែរគេប្រើកិរិយាស័ព្ទនឹងគុណសព្ទជានាមជាច្រើន ឧបមាដូចពាក្យថា: អ្នករែក - អ្នកចូល - អ្នកដើរ - អ្នកទៅ - អ្នកមក ... ស័ព្ទជាកិរិយាប្រែជានាម, អ្នកធំ - អ្នកតូច - អ្នកខ្ជិល - អ្នកប្រសប់-

អ្នកប្រាជ្ញ-អ្នកទៅ... សព្ទជាគុណនាមប្រែជានាម, នាមទាំងឡាយនេះហៅថាការកនាម ។

ចូរចុះសំគាល់ជាពាក្យៈ បកតិ, កិត, សមាស, ការកៈ នៅមុខនាមនិមួយៗ :

ឈើគូស (សមាស) ដំណែង... គោខ្វេ... កាំភ្លើងដៃ...

ផ្លូវ... (បកតិ) ថ្ងៃ... អ្នកស្រែ... សក្យាធិការ...

ដំណើរ... ប្រវែង... ម្តាយមីង...

គុណោបត្ថម្ភ... ដែក... អ្នកប្រាជ្ញ...

ទូកធំ..., គជេន្ទ្រ... អ្នកចាំ...

ជំហាន...: ម្តាយធំ... ឥន្ទ្រាធិរាជ...



ត្រាវស្រែ... ទឹកឃ្មុំ... រថភ្លើង... មហាសេថ...

អ្នកខ្វិល... ផ្ទះផ្សារ... បន្ទាត់... ចតុរង្គ...

មនុស្ស... ទំនិញ... ដៃទៅ... នាគរាជ...

សត្វ...: បានគ្រប... កាំបិតកោរ..., ពានរ...៖

## ៣៨–ប្តាក់ មជ្ឈិមព្យញ្ជនៈ និង ឧត្តមព្យញ្ជនៈ

តន្លុក... សេះទឹម... ឫស្សីស្រុក... យក្សិណី... ។

ពាក្យប្ដូររូបព្រោះផ្លាស់អក្សរសើងជាពាក្យកើតពីព្យញ្ជនៈ វ ។

ឧបមាដូចពាក្យៈ ពិលា = វិលា, ពិសាខ = វិសាខ ។

ចូរផ្លាស់តួ វ ជាតួ ព នូវពាក្យដូចមានតទៅ ៖

វេលា... វេយ្យាករណ៍... វន... វេទី...

វាក្យ... វ្យាធិ... វោមកន្ទ... វេទិតា... វត្តា...

វ្យាបាល... វុត្តិ... វេស្សា... វរ = ព្រះ... វារ...

វៀរ... វ្ឫក្ស... វ្យញ្ជនៈ... វាយុ... ប្រថវី...

វ្ឫហស្បតិ... ។

សេចក្ដីចំណាំ – ពាក្យដែលផ្លាស់ វ ជា ព ច្រើនតែពាក្យបាលី នឹងពាក្យសំស្ក្រឹត ដែលប្រើក្នុងភាសាខ្មែរ ។

## ៣១– ពាក្យកើតពីអក្សរ ឋដ្ឋថស្ឋស្តស្ថ

ពាក្យជាច្រើនកើតពីអក្សរ ឋដ្ឋថស្ឋស្តស្ថ ។ អក្សរ ឋដ្ឋ សម្រាប់តែពាក្យដែលជាបាលី ។ អក្សរ ស្ឋស្តស្ថ សម្រាប់

តែពាក្យជាសំស្ក្រឹត ៗ អក្សរ ថ ប្រែជាពាក្យក្លាយបាលីឬសំស្ក្រឹត ឬជាពាក្យខ្មែរសុទ្ធ ដូចពាក្យៈ បឋម-ឋាន ... ជាបាលី ៗ ប្រថម-ស្ថាន...ជាសំស្ក្រឹត ៗ បថម-ថាន ... ក្លាយ ៗ ថន ...បាលី ៗ ស្តន ... សំស្ក្រឹត ៗ ជេដ្ឋ ... បាលី ៗ ជេឞ្ឋ ... សំស្ក្រឹត ៗ

## វិធីហាត់

ចូរផ្លាស់តួអក្សរ ឋដ្ឋជា ថ-ស្ថ-ស្ត-ស្ឋ តាមដោយភាពរបស់ពាក្យ ៗ ឧបមាដូចពាក្យៈ បឋវី ផ្លាស់ជាប្រថវី ៗ

បឋវី ... ឋន ... ឋលបថ ... ថូប ...

ហត្ថ ... ឋាវរ ... ថលយាន ... សាវត្ថី ...

ឧដ្ឋ ... អធិដ្ឋាន ... ឋានានុក្រម ... ថនិកសត្វ ...

ជេដ្ឋ ... មតិដ្ឋាន ... ឋិត ... ឋិ (គេខ្ចុយទឹកប្រុស)

ឋិតថេរ ... វត្ថុ ... រដ្ឋ ... ឋានិយ ..

ឋាន ... ផយដ្ឋាន ... ថម្ភ ... គោយាគដ្ឋាន ...

## ៣៦ - ព្យញ្ជនៈផ្លាស់រូប

## តែសព្ទគង់នៅដដែល

ពួកអក្សរខ្លះទៀតផ្លាស់រូប តែស័ព្ទរបស់ពាក្យនៅដដែល ដូចពាក្យ: អក្ខរ: ផ្លាស់ជាអក្សរ, ខត្ត ផ្លាស់ ជា ក្សេត្រ, ខ័យ ជាក្ស័យ, ចក្ក ជាចក្រ, បុត្ត ជាបុត្រ, បញ្ញា ជាប្រាជ្ញា, កទ្ទបទ ជាកទ្របទ, បុញ្ញ ជាបុណ្យ, កិច្ច ជាក្រិត្យ, បច្ឆិម ជាបស្ចិម, អច្ឆរិយ ជាអស្ចារ្យ, វិជ្ជា ជាវិទ្យា, មជ្ឈិម ជាមធ្យម, ឈាន ជាធ្យាន, ពជ្ឈ ជាពេធ្យ . . . ។

ព្យញ្ជនៈផ្លាស់ពួកដូចមានខាងលើ គឺ: ១ - ក្ខ ផ្លាស់ជាក្ស, ត្ត - ទ្ធ - ក្ក ផ្លាស់ ជា ត្រ - ទ្រ - ក្រ, ច្ច ជា ត្យ, ជ្ជ ជា ទ្យ, ច្ឆ ជា ស្ច, ញ្ញ ជា ណ្យ - ន្យ, ញ្ញ ជា ជ្ញ, ឈ ជា ធ្យ ។

### វិធីហាត់

ចូរផ្លាស់ពួកព្យញ្ជនៈនៃពាក្យ បើគួរនោះគួរគប្បីផ្លាស់ តាម អធ្យាស្រ័យ ។ ១. សមុទ្ទ - ពុទ្ធចក្ក... ។

| | | | |
|---|---|---|---|
| សមុទ្រ... | វីណាស្រព... | អាទិច្ច... | បញ្ញា... |
| ពុទ្ធបក្ក... | មរក្ខ ... | អមច្ច... | បញ្ញា... |
| ខត្ត, ខត្តិយ... | ទក្ខិណ ... | បច្ឆិម... | សញ្ញា... |
| ខេត្ត... | ខេម... | បច្ចាមិត្ត... | កញ្ញា... |
| បុត្ត... | គហាវាស... | អច្ឆរិយ... | អរញ្ញ... |
| អាយុវ័យ... | បច្ចេក... | វិជ្ជា... | ទុព្ភិក្ខ... |
| អក្ខរៈ... | បច្ច័យ... | ពេជ្ជ, វេជ្ជ... | មាក្ខធម៌... |
| ខណៈ ... | បច្ចូសកាល... | វិជ្ជាធរ... | បិត្ត ... |
| ភក្ខុបទ ... | កិច្ច...... | មជ្ជ ... | មិត្ត ... |
| ខន្តី... | ពាក្យសច្ច ... | មាណវ... | មជ្ឈិម ... |

## ៣៣- អាខ្វាក់អាខ្វិននាំគ្នារត់



មានមនុស្សពិការពីរនាក់ ម្នាក់ខ្វាក់ ម្នាក់ខ្វិន នៅជាវិះគទាំង ពីរនាក់ ប៉ុន្តែម្ចាស់ដោយខ្លួនពីគ្នា ៗ គេប្រើកឲ្យធ្វើការផតអាណាគមេត្តាសោះឡោះ ហើយបុរសទាំងពីរគិតថា: ទីនៃរត់គេចលៃងបំពីគេ ៗ លុះដល់យប់កំនាំគ្នាចុះទៅកំពង់ លួចទូកគេជិះចេញទៅ វាអណ្ដែតឈមមុខទល់គ្នាវិប្រែងអុំ ៗ ខណៈនោះយប់ងងឹតមើលអ្វីមិនឃើញ វាគិតស្មានជាទូកលឿនទៅមុខហើយ តែទូកនោះនៅ

វិលទៅមកនៅត្រង់កំពង់នោះដដែល ៗ លុះភ្លឺឡើងម្ចាស់ចុះមក ឃើញក៏ហៅឲ្យឡើងវិលទៅផ្ទះវិញ ៗ

នៅយូរបានបន្តិចមក អាខ្វាក់អាខ្វិនបបួលគ្នារត់ម្ដងទៀត ហើយពិគ្រោះជាមុនថា: "បើយើងរត់លើកនេះ កុំឲ្យម្ចាស់យើងតាមទាន់ យើងទៅដើរគោកវិញ" អាខ្វាក់ឆ្លើយថា "ទៅផ្លូវម្ដេចបាន បើសុទ្ធតែខ្វាក់ខ្វិនយ៉ាងនេះ" អាខ្វិនឆ្លើយឡើងថា "ឯងកុំព្រួយ ឯងឲ្យអញជិះលើឯង ហើយអញបង្ហាញផ្លូវឯង" លុះដល់យប់ស្ងាត់ អាខ្វាក់លីកអាខ្វិនដើរចេញទៅដល់ស្រុកមួយ អាខ្វិនប្រទះឃើញខ្ទមគេចាំស្រែមួយ ហើយប្រាប់អាខ្វាក់ថា: "វ៉ឺយអាសំឡាញ់ មានខ្ទមមួយមានខ្សែពួរមួយបង្អោយ ចង្អេរមួយនឹងអណ្ដើកមួយធំ" អាខ្វាក់ឮហើយឆ្លើយថា: "អើយយកឲ្យអស់" ៗ អាខ្វិនថា: "យកធ្វើអ្វីធ្ងន់ឥតអំពើ" អាខ្វាក់ថា: "ធ្ងន់អ្វីឯង ធ្ងន់តែអញទេ, ចេះតែយកទៅ" អាខ្វាក់ក៏ប្រមូលយករបស់ទាំងអស់ ក្នុងខ្ទមនោះមានបាយមួយឆ្នាំងធំ ដែលគេដាំទុកនៅជើងក្រានអាក៏យកទាំងអស់ស្រេច

ហើយគាត់ខំទៅឡើងជិះលើគាត់ម្នាក់ទៀត ឯគាត់ម្នាក់ជាមនុស្សខ្លាំងយករបស់ទាំងនោះទៅបាន ។

## ៣៤–សុភាទន្សាយបានសង្គ្រោះ

ត្រី - កំពឹស - ក្តាម - ខ្យង ឲ្យរួចជីវិត

ទន្សាយទៅដល់មាត់បឹង ឃើញសត្វទាំងឡាយកំពុងតែបាចទឹក កំបេះស្លឹកឈើដែលមានដង្កូវវារមានស្នាមក្រវែមក្រវ៉ាមមកក្នុងធ្វើជាសំបុត្រ ហើយស្រែកហៅសត្វទាំងឡាយនោះថា: “នែបងប្អូនទាំងអស់គ្នាស្តាប់ខ្ញុំ ! ព្រោះព្រះឥន្ទ្រឲ្យខ្ញុំនាំសំបុត្រនេះមកប្រកាសប្រាប់អស់អ្នកគាល់គ្នាថា: “ព្រះឥន្ទ្រលោកនឹងមក កាប់ដើមត្រែឲ្យខ្ទីនដើមអក កាប់ក្បាលចបកដកក្តុកដីសារ កាប់ក្បាលគាខ្ញាឲ្យជ្រៅៗជាងគេ វះពោះគាគេ កាត់កគាថ្មាន់ ។ សត្វទាំងអស់ឮដូច្នោះភ័យណាស់ ផ្អើលគោះឡោះបោលជាន់លើគ្នា ដរីគ្រប់ មោស រមាំង ខ្លា គេ ស្ទុះបោលទៅជាន់លើពស់



ហ៊ានដែលធ្វើជាទំនប់ ដាច់ខ្ទួនជាពីរបីកំណាត់ ធ្លាយទឹកលិច ស្លាប់អស់សត្វទាំងនោះទៅជាចំណីត្រីនិងអណ្ដើកវិញ ។

តាំងអំពីថ្ងៃនោះមកសត្វទាំងអស់សឹងគោរពខ្លាចប្រាជ្ញាទន្សាយ ហើយហៅថាសុភាទន្សាយទាំងអស់គ្នាអំពីថ្ងៃនោះមក ។



## ៣៥_វិជ្ជាសម្បត្តិ

វិហសាផ្តុំផលទាំងអស់គ្នា ចំណេះវិជ្ជាទាំងសម្មាយ

មានគុណវិសេសធំធ្លាយ គួរយើងរៀបរក្សាយកុំខ្វាបធ្វន់ ។

មិនលំបាកទុកស្រណុកណាក់ ជាជាងមាសប្រាក់សព្វទ្រព្យធន

មិនខ្លាចចោរលួចចោរប្លន់ ទៅគ្រប់ជម្ពូគ្រាន់ជាស្បៀង ។

ឥតកណ្ដៀរកោរកណ្ដុរកាត់ ចាយណាស់មិនបាត់មិនមានល្អៀង

ប្រើច្រើនកើតច្រើនចំរើនទៀត ពីបច្ចុប្បន្នរៀងទៅបរលោក ។

មានសុវិជ្ជាគង់មានទ្រព្យ អ្នកផងមិនស្អប់មិត្តមូលមក

មានមិត្តហើយបុណ្យក៏គង់កើតក រួចទៅបរលោកយានស្ថានបុត្ត ។

## ៣៦- នាងកង្រីថ្វាយសេចក្ដីស្ងាត់ កំបាំងដល់រទ្ធិសែន

ប្រពាតសួនរួចហើយ ទៅដល់មុខទ្វារឃ្លាំទឹកគូបបុប្ផា នៅស្ងាត់ដាច់សន្ធែនឆ្ងាយពីកន្ទែនដទៃ នាងកង្រីឈប់ស្ងាំងកាំងកាន់តាំងស្មារតី ហើយភ័យណាស់ ទើបទូលស្វាមីថា៖ ឃ្លាំងនេះមានការសម្ងាត់ មាតាខ្ញុំម្ចាស់ហាមផ្ដាច់មិនឲ្យប្រាប់អ្នកណាឲ្យដឹងថាមានរបស់អ្វីៗ នោះឡើយ ។

នាងរិតចូលទៅជិតស្វាមីហើយទូលថា៖ ក្នុងឃ្លាំងនេះ នៅលើគុម្ពមានពានប្រាក់មួយក្រឡៃមាស ក្នុងពាននោះមានខ្លែកស្រីពីរដណ្ដប់ទាក់ ហើយនៅជិតពាននោះមានផបមួយ ក្នុងផបនោះមានថ្នាំដាក់ខ្លែកខ្ទាក់ឲ្យជាវិញ ។ បើអ្នកណាខ្ទាក់ខ្លែកជ្រុះប្រស្រើរចេញ គ្រាន់តែវាក់គ្រាប់ខ្លែកក្នុងរន្ធដុំទៅវិញ ហើយលាបថ្នាំនេះទៅ នោះខ្លែកនឹងជាឡើងហើយគឺដូចដើមវិញហោង ។



រិទ្ធិសែនរំភើបសង្កត់ព្រះទ័យអំពីសេចក្ដីទុក្ខសោក ហើយស្ដេចនាំនាងកន្ទ្រីវិលទៅប្រាសាទវិញរហ័សហាន់ ។

លុះដល់យប់ ពេលសោយក្រយាស្ងាយ រិទ្ធិសែនបំផឹកស្រានាងកន្ទ្រី ហើយទាំងពួកពលយក្សទាំងអស់ឲ្យស្រវឹងគ្រប់គ្នា លង់លោមឲ្យដេកលក់ទៅ ហើយលបយកកូនសោទ្វារឃ្លាំងពីនាងកន្ទ្រីបាន ។ ស្ដេចយាងទៅយកត្រែកនាងពីរដណ្ដាប់ យកដបថ្នាំ ហើយទាំងដំបងផង ។ ទើបស្ដេចយាងមកឧបច្ចម លានាង

ក្រនីដែលកំពុងដេកលក់មិនដឹងខ្លួនសោះនោះ   រួចឡើងគង់សេះរត់ទៅ ៗ

## ៣៧- សត្វទុងនឹងត្រី



មានសត្វទុងមួយ ជាសត្វកាន់សក្កាយទិដ្ឋិ ៗ ថ្ងៃមួយវាចេញស្វែងរកចាប់ត្រីជាអាហារ ៗ លុះហោះទៅបានឃើញត្រីក្អិតមួយ នៅខាងមាត់ខ្លួន ទុងនោះក៏ចឹកត្រីក្អិតនោះបាន ទើបមកគិតថា អាត្មាអញនេះជាបក្សីរូបធំត្រូវតែបរិភោគត្រីធំ ៗ យ៉ាងត្រីរ៉ស់ ត្រីឆ្តោ ត្រីប្រាជាដើម នោះទើបសមនឹងសក្តិយសរូបអញនេះ អាត្រីក្អិតរូបតូចមួយនេះមិនសមគួរនឹងរូបអញឡើយ គិតហើយទុងក៏លែងចោលបង់ ហើយហោះទៅមុខទៀត បានយល់ត្រីចង្វាក្រៀងមួយ ទុងក៏ចឹកបានឡើងនឹងស៊ី ក៏គិតថា: ត្រីចង្វាក្រៀងនេះតូចពេកណាស់ ពុំគួរនឹងរូបអញជាធំ គិតហើយ

ក៏លែងត្រីនោះទៅលបទេ ហើយខំហែលទៅស្វែងរកតាមមុខទៀត ស្វែងទៅៗ រកត្រីពុំបាន ពេលសោតក៏ខំទទាបល្ងាចទីផុតពេល ស្វែង ទុំនោះឯង កើតក្ដីឃ្លានអាហារមហិមា ទំស្វែងរកអាហារពុំបានឡើយ ម្ល៉ោះហើយទុំកើតទុក្ខ មុខស្រពោនកើតក្ដៅចិត្ត គិតក្រោយអាហារដែលខ្លួនរកបានអំពីព្រឹក ។

## ៣៨ — ស្ត្រីពីរនាក់ដណ្ដើមកូនគ្នា

មានស្ត្រីពីរនាក់មានកូនដូចគ្នា ម្នាក់កូនទើបនឹងស្លាប់ទៅ ម្នាក់កូននៅរស់ហើយពកូនយកទៅផ្ងូតទឹក ។ ឯស្ត្រីកូនស្លាប់នោះ ដើរមកជួបហើយស្រដីថា: "កូននាងដូចកូនអញណាស់ នាងអើយ អញសូមបីបកូននាងបន្តិច" ។ នាងម្ដាយក៏ឲ្យកូនទៅ ស្ត្រីនោះទទួលយកមកបីបំបៅហើយយកកូនគេដើរទៅលំនៅខ្លួន ។ នាងម្ដាយស្រែកហៅថា: "នាងអើយ ! នាងយកកូនអញទៅឯណា" ។ ស្ត្រីនោះតបថា: "កូនអញទេតើ ម្ដេចក៏មកថាកូនឯង" ។ ម្ល៉ោះហើយឈ្លោះប្រកែកគ្នាទៅវិញទៅមក រួចនាំគ្នាទៅប្ដឹងចៅក្រម ។



ចៅក្រមជំនុំពិភាក្សាកាត់សេចក្តីនេះពុំបាន ទើបនាំស្ត្រីទាំងពីរនោះឡើងទៅ ក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជដោយនូវដំណើរនោះៗ ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ ហើយត្រាស់ឲ្យយកកូននោះទៅដាក់នៅទីកណ្ដាលឲ្យដណ្តើមគ្នា ត្រាស់ថា៖ បើនរណាដណ្តើមបាន ឲ្យអ្នកនោះយកកូននោះចុះៗ

កាលបើដូរបោះកូរ ស្ត្រីទាំងពីរចូលដណ្តើមគ្នា, ឯស្ត្រីស្អប់កូន ចាប់ទាញយូរពុំគិតបាក់បែកហែកដៃជើង ឥតករុណាប្រណី

ថាក្មេងឡើយ ៗ ឯម្ដាយយល់ឃើញមេនោះរាំទុះការប្រាប់កូន ចាប់ពុំគិតបាក់បែកឡើយក៏លែងកូនឲ្យបាន ទៅវាទៅ ៗ ទើបព្រះអង្គមានព្រះបន្ទូលត្រាស់ថា : ព្រះវៃប្ដូនលែងកូនឲ្យបានទៅគេនោះ ហេតុដ្បិតអាសូរករុណាកូន ព្រោះស្ដ្រីនោះឯងជាម្ដាយពិតមែន ។ ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទ្រង់កាត់សេចក្ដីឲ្យបានកូននេះទៅម្ដាយវិញ រីឯមេដណ្ដើមកូនគេនោះ ព្រះអង្គឲ្យផ្ដន្ទាទោស ៗ

## ៣៩ - រឿងខ្លាឃ្មុំនិងដើមពង្រ

ខ្លាឃ្មុំមួយ ទៅដេកនៅក្រោមដើមពង្រ ១ ដើម

លុះដេកលក់បន្តិចទៅ ផ្លែពង្រធ្លាក់ធ្លាក់មកត្រូវក្បាល ខ្លាឃ្មុំ



ក៏ភ្ញាក់ក្រោកឡើងម៉ឹមម៉ាបាន ក្ដីឈឺក្បាលពន់ពេកណាស់ក៏

ដើរចេញពាក់ទីនោះ ហើយទឹកចិត្តនឹងដើមពង្រក៏បង់ការឃាត ។ គ្រាកាលនោះ មានអ្នករទេះម្នាក់បររទេះមកត្រង់ទីនោះ ជួនជាភ្លៅរទេះបាក់ក៏ឈប់ ហើយគាត់ចូលទៅដើរចូលព្រៃ ដើម្បីនឹងកាប់ឈើធ្វើភ្លៅរទេះ ។ លុះដើរៗទៅបានជួបនឹងខ្លាឃ្មុំកណ្ដាលព្រៃ ។ ខ្លាឃ្មុំក៏សួរថា: អ្នកបងឯងដើររកអ្វី តានោះក៏ប្រាប់ថា: យើងដើររកកាប់ឈើធ្វើភ្លៅរទេះ ខ្លាឃ្មុំបានឮកាសទើបប្រាប់ទៅថា: ឈើសម្រាប់ធ្វើភ្លៅរទេះ គ្មានឈើអ្វីជាប់ស្អិតដូចដើមពង្រទេ ចូរអ្នកឯង ទៅកាប់ដើមពង្រឯណោះចុះ ។ អ្នករទេះក៏ចូលទៅកាប់ដើមពង្រនោះ តាមខ្លាឃ្មុំប្រាប់ ។ ឯដើមពង្រនោះជាលំនៅនៃរុក្ខទេវតា ។ កាលបើឃើញមនុស្សកាប់លំនៅខ្លួនដូច្នោះ ក៏ចេញមកសួរថា អ្នកកាប់ដើមពង្រដើម្បីការអ្វី? តានោះប្រាប់ថាយកទៅធ្វើភ្លៅរទេះ ដ្បិតខ្លាឃ្មុំបានប្រាប់ថា ឈើនេះជាប់ល្អណាស់ ។ រុក្ខទេវតាដឹងថាខ្លាឃ្មុំចងគំនុំនឹងដើមពង្រក៏ប្រាប់ថា បើបានខ្លាញ់ខ្លាឃ្មុំមកលាបនោះ ទើបស្អិតជាប់ល្អបរទៅសប្បាយ បើដូច្នេះចូរអ្នកឯងទៅសម្លាប់ខ្លាឃ្មុំយកខ្លាញ់វាទុកលាបភ្លៅរទេះអ្នកទៅ ។

## ៤០ - ឆ្មាស្រុកនឹងចាបពូក



ឆ្មាស្រុកមួយ ចាបពូកមួយ នៅជាមួយគ្នា ៗ ថ្ងៃមួយមានចាបព្រៃហើរមកទំនៅជិតចាបពូកនោះ ហើយពោលពាក្យគំរះផ្សៀល ចាបនៅក្នុងទ្រុង ចាបក្នុងទ្រុងក៏កើតទាស់ទាល់ឡើង ទើបដេញប្រទេញទៅចាបព្រៃវិញ ៗ ជម្លោះដេញគ្នាទៅវិញទៅមកក៏កើតឡើងតែនឹងប្រចឹកគ្នាពុំបាន ព្រោះមួយនៅក្នុងទ្រុង មួយនៅក្រៅទ្រុង ៗ ឯឆ្មាស្រុកបានឮចាបទាំងពីរឈ្លោះគ្នាដូច្នោះ ក៏រឹងហើយគិតថា "អាសត្វចង្រៃ ហេតុអ្វីមកឈ្លោះប្រកែកនឹងចាបជាសំឡាញ់អញអេះ, បើដូច្នេះអញនឹងជួយចាបជាសំឡាញ់ចុះ" ៗ គិតហើយឆ្មានោះចាប់ចាបព្រៃនោះបាន ហើយទំពាស៊ីជាឆ្ងាញ់ ៗ "ឱ! អញមិនដឹងថាសាច់ចាបព្រៃមានរសជាតិឆ្ងាញ់ដល់ម្ល៉េះសោះ បើដូច្នេះ ចាប់ដើមតាំងពីថ្ងៃនេះទៅ អញនឹងស្វែងរកចាប់ចាបព្រៃ

ស្រ័យ" ។ ឆ្មានោះគិតដូច្នោះហើយ ពីថ្ងៃនោះមក តាំងតែស្ទួង លបចាប់ចាបព្រៃកស្រ័យជានិរន្តរ៍ ។ ថ្ងៃមួយឆ្មានោះរកចាប់ចាបព្រៃពុំបាន ដោយញ៉ាំមាត់អត់ពុំបាន ក៏ហែកទ្រុងចូលទៅចាប់ចាបជាសំឡាញ់បរិភោគតាមក្តីប្រាថ្នាហោង ។

## ៤១- ល្ពៅនឹងប្លុកទំពក់នៅដៃ

មានអមាត្យមួយនាក់ តែងរក្សាដើមល្ពៅព្រះរាជទ្រព្យព្រះមហាក្សត្រាធិរាជ គាត់កាប់ផ្លែល្ពៅនោះរៀងរាល់ថ្ងៃ បើមានផ្លែណាទុំគាត់បេះទៅថ្វាយស្តេច ។ គាប់ជួនថ្ងៃមួយមានបុរសម្នាក់យកទំពក់ទៅបេះផ្លែល្ពៅអំពីព្រៃឯទៀត ។ តែបុរសនោះលើទំពក់ដក់ផ្លែល្ពៅដើរទៅទៀបខាងដើមល្ពៅ អមាត្យមើលទៅយល់បុរសនោះមានទំពក់នៅដៃ នឹងផ្លែល្ពៅ នៅប្លុក ទើបគាត់ទៅកាប់ផ្លែល្ពៅរបស់គាត់មើល លុះពិនិត្យទៅឃើញទងទខ្វះ ទើបគាត់គិតថា៖ នេះសមអាលើទំពក់បេះផ្លែល្ពៅនេះ ដក់ទៅអំបាញ់មិញនេះឯងជាចោរលួចបេះផ្លែល្ពៅស្តេចមិនខានឡើយ ។ ទើបអមាត្យក៏រត់ទៅតាម

# ៩៦ — ថ្នាក់ មន្ត្រីមង្គល និង ឧត្តមង្គល



ចៅនោះ ឃើញផ្លែត្នោត ទាំចុកចំពក់នៅដៃ ហើយគេក៏យកចៅ នោះទៅក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជ ដោយដំណើរសព្វ គ្រប់ ៗ ព្រះអង្គមានព្រះបន្ទូលថាកុំអាលគាប់វាឡើយ ឲ្យយកផ្លែ ត្នោតនោះទៅផ្សាប់នឹងទង បើវាត្រូវទំលាក់អំពីទងនោះមកដី មើល វាជ្រុះទៅត្រង់ណាឲ្យពិចារណាតាមដោយឡូវហេតុនោះ ហោង ៗ

អមាត្យយកផ្លែល្ពៅទៅផ្សាប់នឹងទងនោះមិនត្រូវឡើយ ព្រះអង្គបង្គាប់ឲ្យទំលាក់មកដី ផ្លែល្ពៅជ្រុះទៅក្នុងថុកកក់ រួចព្រះអង្គឲ្យគេកាយកក់យកផ្លែល្ពៅនោះមកវិញ ។ ព្រះអង្គឲ្យយកផ្លែល្ពៅជ្រុះពីថ្ងៃមុននោះទៅផ្សាប់នឹងទងដដែល មើលឃើញត្រូវមែន ទើបទ្រង់ព្រះរាជទានផ្លែល្ពៅដែលដក់ទៅបោះនោះវិញ បុរសនោះក៏ក្រាបលាយករំពក់ទឹងផ្លែល្ពៅទៅបំនៅអាត្មា ។

## ៤២– រឿងសត្វបក្សី

មានសត្វបក្សីមួយ អាស្រ័យនៅលើខ្លោងទ្វារព្រះរាជវាំងនៃព្រះបាទវិទេហរាស្ត្រ នៅក្នុងនគរមិថិលា បក្សីនោះបានឃើញស្តេចយាងចេញចូលតាមទ្វារនោះកាលណា ក៏ចុះមកដើរធ្វើសិរសីផ្ងក់ៗ គឺគំនាប់គោរពព្រះបរមរាជាតែរាល់ៗ កាល ។ ឯព្រះបាទវិទេហរាស្ត្រ ស្តេចយល់អាការកិរិយាបក្សីនោះហើយក៏ត្រាស់សួរទៅមហោសថបណ្ឌិតពោធិសត្វ ក្រាបទូលតាមហេតុដែលបក្សីនុះខ្គុំចំពោះបរមរាជា ទើបស្តេចមានព្រះហឫទ័យ

ត្រកកអរនឹងបក្ស័យនោះឯង ហើយទ្រព្យប្រាសប្រាណព្រោះកជទាន មាសមួយពែក្តាម បើកឲ្យនាយពិសេសទិញសាច់ឲ្យបក្ស័យ អាស្រ័យតាមកាលសម័យពីថ្ងៃនោះមក ឯបក្ស័យក៏បានទៅសុខសប្បាយពុំបានខ្វល់ខ្វាយចេញទៅស្វែងរកអាហារឯណាឡើយ ។

## ៤៣ -- អទិន្នបុព្វកៈ

មានព្រាហ្មណ៍ម្នាក់ឈ្មោះអទិន្នបុព្វកៈ នៅក្នុងនគរសាវត្ថី ។ បានជាឈ្មោះដូច្នេះដោយហេតុថា ព្រាហ្មណ៍នោះជាមនុស្សកំណាញ់ កាញ់សម្បត្តិទុក មិនដែលបរិច្ចាគទ្រព្យ ចេញធ្វើបុណ្យឲ្យទាន ដល់សមណព្រាហ្មណ៍ ឧនិសូម្បីយាចកទាំងឡាយឡើយ ។ ព្រាហ្មណ៍នោះមានកូនប្រុសម្នាក់ឈ្មោះមដ្ឋកុណ្ឌលី បានជាមានឈ្មោះដូច្នេះព្រោះកូននោះចំរើនធំឡើងហើយ អទិន្នបុព្វក-ព្រាហ្មណ៍ជាបិតាប្រារព្ធនឹងធ្វើកុណ្ឌលជាគ្រឿងបំពាក់ឲ្យនោះនឹង ពៅដូលជាធនធនធ្វើក្រែងថង់ថ្លៃឈ្នួល ទើបព្រាហ្មណ៍យកមាសមកដំដោយខ្លួនឯងធ្វើកុណ្ឌល ។ លុះចំណេរមក មដ្ឋកុណ្ឌលី

នោះមានជម្ងឺឈឺ គឺរោគលឿង ។ ទើបនាងព្រាហ្មណីនិយាយនឹងប្ដីថា: អ្នកអើយកូនយើងស្គម កើតលឿងឈឺនៃយ៉ាងនេះ គួរអ្នកទៅរកគ្រូពេទ្យមកមើលមករក្សា, ឯព្រាហ្មណ៍ជាអ្នកខ្លាចបង់ខាតសម្បត្តិ ក៏ធ្វើព្រងើយកន្តើយមិនអើពើក្នុងការរកគ្រូមករក្សាកូនឡើយ ។ ឯរោគកូននោះរឹងរឹតតែឈឺធ្ងន់ឡើង ព្រាហ្មណ៍យល់អាការរោគកូនកាន់តែឈឺធ្ងន់ ទើបគិតថា « កូនអញនឹងទុកឲ្យនៅក្នុងផ្ទះនេះយល់ជាពុំបាន ព្រោះពួកញាតិមិត្តទាំងឡាយគេចូលមកសួរជម្ងឺ គេនឹងឃើញទ្រព្យសម្បត្តិអញ ហើយគេនឹងមកកួនខ្ចីប្ដូរសុំអញ » ។ ព្រាហ្មណ៍នឹងប្រពន្ធនាំគ្នាសែងគ្រែកូនចេញមកដាក់នៅល្វែងតាកផ្ទះ ។ ឯចៅមដ្ឋកុណ្ឌលីកុមារនោះ លុះរោគកំរើកខ្លាំងឡើងហើយ ក៏ដល់នូវកាលកិរិយាក្ស័យក្នុងកាលនោះហោង ។

# ៤៤ - ស្ទូចត្រី

ក្មេងពីរនាក់ គឹមនិងសាន រៀនទៅសាលាជាមួយគ្នា



ថ្ងៃឱកាសថ្ងៃព្រហស្បតិ៍ ក៏ទៅស្ទូចត្រី នៅមាត់ស្ទឹងសែន ។ លុះព្រឹកឡើងវា នាំគ្នាចេញទៅពីព្រលឹម ដ៏មាន សម្លៀកបំពាក់ចាស់ៗ មួកធំដើម្បីបាំង ចំហាយព្រះអាទិត្យផង ។ ចៅគឹមលីដងសន្ទូចមួយ ដ៏មានខ្សែថ្មី សន្ទូចកំសួលទឹងប្រអប់ស៊ីវិឡាតដាក់នុយ ។ ចៅសានកាន់ល្អី ស្បៀងអាហារ ។ ក្មេងទាំងពីរនាក់ទៅឈប់នៅកន្លែងមួយ នាមាត់ទឹកដ៏មានម្លប់ល្អ ក៏ស្ទូចនៅទីនុះ ។ ដម្បូងគ្មានត្រីមកស៊ីសោះ គឹមនិងសានពុំហ៊ានកំរើកខ្លួនឡើយ ក្រែងត្រីផ្អើល ។ មួយស្របក់ មានត្រីប្រចៀនហែបហែលនាខ្នងទឹក ។ កំសួលសន្ទូចកញ្រោល ឡើងម្ដងៗ តែត្រីស៊ីសន្ទូចវាត់ផងសន្ទូចឡើងបានត្រី ។ មិនយូរ

ប៉ុន្តែនៅបានត្រីពេញត្រកនៅសប្បាយចិត្តក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ ។ ម្តាយនៅទាំងពីរនាក់ក៏មានសេចក្តីរីករាយ ហើយយកត្រីធ្វើម្ហូបស៊ីបាយ ។

## ៤៥- ផ្លែមង្ឃុត

សានទីនិងខុំកាន់ដៃគ្នាដើរលេង ។ ដើរបានបន្តិចទៅ



ប្រទះផ្លែមង្ឃុតមួយនៅកណ្តាលផ្លូវ ។ សានទិយាយថា: ផ្លែមង្ឃុតនេះត្រូវបានអញ ព្រោះអញបានឃើញមុន ។ ខុំថាត្រូវបានអញទេ ព្រោះអញរើសបាន ។ ក្មេងទាំងពីរនាក់ចេះត ដជែកហៀបតែប្រវាយប្រតប់គ្នា ។ មានក្មេងម្នាក់ទៀត ឈ្មោះសារី មកដល់ទីនោះ វាឈរនៅចន្លោះក្មេងទាំងពីរ ហើយសួររកដើមហេតុ រួចក៏យកកាំបិតបកពីហោប៉ៅអាវ វាពុះមង្ឃុតជាពីរ

ហើយនិយាយថា៖ សំបកមនុស្សមួយចំហៀងនេះ ត្រូវបានទៅសាខ ដែលបានឃើញមុន ឯសំបកមួយចំហៀងនេះទៀតត្រូវបានទៅខ្ញុំ ដែលបានរើស, រីឯអញ ដូចជាគេថា តែធ្វើការអ្វីត្រូវមានឈ្នួល, បើដូច្នេះ អញត្រូវបានសាច់ ជារួចហើយ សារីតាមសាច់មនុស្សទៅៗ

## ៤៦ - ដេញចាប់ចោរៗចាប់វិញ



បុរសមួយនាក់កើតលើសាលា ៗ អាចោរម្នាក់លួចគោគេ

ដេញឈ្លូទៅ ៗ បុរសដេកលើសាលា ក៏ស្ទុះលោតចុះទៅចាប់បានអាចោរ ៗ លុះម្ចាស់គោតាមទៅទាន់ អាចោរស្រែកប្រាប់ទៅថាៈ ចៅនេះឯងលួចគោអ្នក ៗ ឯបុរសដេកលើសាលាឆ្លើយឡើងថាៈ ចៅឯងលួចគោគេអញចាប់ចៅឯងបាន ម្ដេចចៅមកថាអញវិញ ៗ ម្ចាស់គោយល់ថាប្រកែកគ្នាដូច្នោះហើយទើបចាប់តែម្នាក់ឯងខ្លាចក្រែងពុំមែនចោរនោះ ទើបចាប់មនុស្សទាំងពីរទៅប្ដឹងចៅក្រមឲ្យជំនុំជំរះ តាមពាក្យបណ្ដឹងទាំងសងខាង ៗ ចៅក្រមពិចារណាកាត់សេចក្ដីនោះពុំបានឡើយ ក៏នាំឡើងទៅក្រាបទូលក្សត្រាធិរាជដោយដំណើរនោះ ៗ ព្រះអង្គទ្រង់ព្រះចិន្ដាត្រាស់បង្គាប់ឲ្យយកមនុស្សទាំងពីរនាក់នេះទៅចងឲ្យមូសខាំ ហើយឲ្យអមាត្យទៅលបចាំស្ដាប់ពាក្យចៅទាំងពីរនោះ ៗ ចៅដែលដេកលើសាលាពោលរអ៊ូថាៈ បទៃតែឯង លួចគោគេទើបគេចងអញឲ្យមូសខាំ ៗ អាចោរថាអញលួចតែអញ ហេតុអ្វីក៏ទៅចាប់អញ

ព្រោះតែចាប់អញ ទើបគេបានអញមក អមាត្យកត់ពាក្យចៅទាំងពីរនោះ ហើយនាំឡើងទៅថ្វាយក្សត្រាធិរាជ ព្រះអង្គបង្គាប់ឲ្យពិន័យតាចោរមួយជាបួន គឺយកទ្រព្យដើមចេញ ហើយចែកក្រយាពិន័យជាភាគបី ភាគមួយបានទៅម្ចាស់គោ ភាគពីរបានទៅចៅដែលចាប់បានខ្លួនចោរនោះ ។

ការផ្សាយរបស់

បណ្ណាគារ គិម-សេង

លេខ ២២៣ វិថីព្រះមុនីវង្ស

ភ្នំពេញ

តម្លៃ